## តើបុណ្យណូអែលគេធ្វើអ្វីខ្លះ?

ព្រះនៃនគរស្ថានសួគ៌បានយាងចុះមកហើយ...! បងប្អូនទាំងអស់គ្នាដែលដឹងទេថា ហេតុអ្វីបានជាព្រះយាងចុះមកផែនដីដែលមានពេញដោយអំពើបាបនេះ? សម្រាប់បងប្អូនដែលមិនមែនជាគ្រីស្ទបរិស័ទប្រហែលជាពុំសូវដឹងអំពីសាច់រឿងដ៏អស្ចារ្យមួយនេះ! តែចំពោះបងប្អូនដែលជាអ្នកជឿ ប្រាកដជាទទួលបានព័ត៌មានច្រើនអំពីបុណ្យណូអែល ពីព្រោះស្ទើរតែគ្រប់ព្រះវិហារទាំងអស់លើពិភពលោកនេះបានប្រារព្ធពិធីរម្លឹកកំណើតព្រះគ្រីស្ទជារៀងរាល់ឆ្នាំ។ ប៉ុន្តែ ភាគច្រើនពុំសូវចាប់អារម្មណ៍លើដង្វាយទាំងបីប្រភេទដែលពួកហោរ ពីទិសខាងកើតដែលបានថ្វាយដល់ព្រះរាជបុត្រា ថាមានន័យដូចម្ដេចឡើយ? កូនសៀវភៅមួយនេះនឹងជួយប្រាប់ដល់បងប្អូនអំពីអត្ថន័យដ៏ពិតនៃពិធីបុណ្យណូអែល ព្រមទាំងរឿងរ៉ាវផ្សេងៗទៀតដែលទាក់ទងជាមួយព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ។

«បើគ្មានព្រះគ្រីស្ទ នោះក៏គ្មានក្ដីសង្ឃឹមដែរ»។
( លោកគ្រូ ឆាល ស្ពើចិន )

ផ្លូវពិត
plovpit.com

ISBN 978-9924-566-05-2
9 789924 566052


អត្ថន័យ
ណូអែល
THE MEANING OF CHRISTMAS

# អត្ថន័យ

# ណូអែល

THE MEANING OF CHRISTMAS

ផ្លូវពិត
plovpit.com

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម @ ២០២២
និពន្ធដោយ៖ អ្នកគ្រូ Christina Fox, អ្នកគ្រូ Nancy Guthrie, លោកគ្រូ David Mathis,
លោកគ្រូ John Piper, ក្រុម Got Questions, លោកគ្រូ Tony Reinke, លោកគ្រូ Stephen J. Wellum
និងលោកគ្រូ Jared Wilson
បកប្រែដោយមានការអនុញ្ញាត
All rights reserved by original authors © 2022
Used by permission
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
បកប្រែដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់ និងលោក ទេព រ៉ូ
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក អ៊ុន ជ័យរិទ្ធ, កញ្ញា ថន ស្កាពរ, លោក ឯក ម៉ានិល, លោក ជឿន ជីវិចន្ទា, កញ្ញា ជឿន ចាន់លាប, កញ្ញា ខឹម ផល្លី, កញ្ញា យ៉ុន សាឯម, លោកស្រី ធី លីដា, លោក ថាច់ ទិត្យសូរិយា, កញ្ញា អ៊ូ គឹមហ៊ុន, លោកស្រី ឈឿន សុផាន់ណា, លោកស្រី សំ ថាវី,
លោកស្រី ឡូញ ស្រីរដ្ឋ, លោកស្រី ឡូញ ណារ៉ុង, លោក ម៉េង មនោ,
លោក ខែម បូឡុង, លោក ប៊ុន ធីម៉ូថេ, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ

ការប្រើប្រាស់បទព្រះគម្ពីរបរិសុទ្ធ និងដ៏វិសុទ្ធ និងព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤មានការអនុញ្ញាតពីសមាគមព្រះគម្ពីរកម្ពុជា និងរក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត។ មានការអនុញ្ញាតការប្រើប្រាស់បទព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ-សញ្ញាថ្មី រក្សាសិទ្ធិ © ២០១២ ព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។ យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក ឯក ធីម៉ូថេ

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ www.plovpit.com
បោះពុម្ពលើកទី១ ចំនួន២០០០ក្បាល គ.ស. ២០២២ នៅព្រះរាជាណាចក្រកម្ពុជា

# មាតិកា


១. តើគ្រីស្ទបរិស័ទគួរប្រារព្ធពិធីបុណ្យណូអែលដែរឬទេ? ........ ៥

២. តើអ្វីទៅជាអត្ថន័យបុណ្យណូអែល? ........ ១១

៣. ណូអែលរាត្រីនេះ ........ ១៧

៤. ព្រះបានយាងចុះមក ........ ២១

៥. ការយាងមកយកកំណើតជាមនុស្ស ........ ២៩

៦. ការចែកចាយទីបន្ទាល់នៅពេលណូអែល ........ ៣៩

៧. ៥ចំណុចសម្រាប់បង្រៀនកូនៗពេលបុណ្យណូអែល ........ ៤៥

៨. អ្នកកាន់ទុក្ខប្រាថ្នា ........ ៥១

៩. ការអស្ចារ្យនៃការដែលព្រះបន្ទូលបានយាងមក ........ ៥៩

១០. វេលាកំណត់បានមកដល់ ........ ៦៥

កំណត់យោង ........ ៧១

អានបន្ថែមនៅ៖ ........ ៧២

ហើយទាញយកសៀវភៅជាច្រើនទៀតដោយឥតគិតថ្លៃនៅ៖ ... ៧២

# ១ តើគ្រីស្ទបរិស័ទគួរប្រារព្ធពិធីបុណ្យណូអែលដែរឬទេ?

ការជជែកវែកញែកគ្នាដេញដោលអំពីសំណួរដែលលើកឡើងថា តើគ្រីស្ទបរិស័ទគួរ ឬក៏មិនគួរប្រារព្ធពិធីបុណ្យណូអែល គឺជាព្រឹត្តិការណ៍មួយដែលបាន ហើយនឹងកំពុងនៅតែបន្តកើតឡើងអស់ជាច្រើនសតវត្សរ៍មកហើយ។ មានភាគីគ្រីស្ទបរិស័ទដែលប្តូរផ្តាច់ជំនឿយ៉ាងស្មោះត្រង់ចំនួនស្មើគ្នារវាងក្រុមទាំងពីរដែលនិយាយទាក់ទងទៅនឹងការជជែកគ្នាមួយនេះ ហើយភាគីទាំងពីរមានមូលហេតុជាច្រើនថាគ្រីស្ទបរិស័ទគួរ ឬក៏មិនគួរប្រារព្ធពិធីបុណ្យណូអែលក្នុងផ្ទះរបស់ខ្លួន។ ប៉ុន្តែ តើព្រះគម្ពីរមានចែងយ៉ាងដូចម្តេចខ្លះ? តើព្រះគម្ពីរបានលើកឡើង ព្រមទាំងផ្តល់ជូនការណែនាំយ៉ាងច្បាស់ថា តើគ្រីស្ទបរិស័ទគួរ ឬក៏មិនគួរប្រារព្ធពិធីបុណ្យណូអែលដែរឬអត់?

តោះ! ជាដំបូង ចូរយើងនាំគ្នាមើលអំពីមូលហេតុដែលគ្រីស្ទបរិស័ទមួយចំនួនមិនប្រារព្ធពិធីបុណ្យណូអែលជាមុនសិន។ ការជជែកគ្នាមួយទាស់នឹងពិធីបុណ្យណូអែលគឺថា ទំនៀមទម្លាប់នៅជុំវិញពិធីបុណ្យមួយនេះមានដើមកំណើតចេញពីប្រភពដែលមិនមែនជាគ្រីស្ទសាសនា។ ការស្វែងរកព័ត៌មានដែលអាចទុកចិត្តបានលើប្រធានបទមួយនេះគឺពិតជាពិបាកណាស់ ពីព្រោះដើមកំណើតជាច្រើននៃទំនៀមទម្លាប់របស់យើងសុទ្ធតែមានប្រភពដែលយើងមិនសូវដឹងយ៉ាងច្បាស់ ដែលជារឿយៗក៏ជាប្រភពទាស់ប្រឆាំងនឹងគ្នាទៀតផង។ កណ្តឹង ទៀន របស់របរតាំងលម្អនានា និងពេលវេលានៃរដូវកាលគឺសុទ្ធតែមានការរៀបរាប់ក្នុងប្រវត្តិសាស្ត្រនៃការថ្វាយបង្គំរបស់ពហុទេពសាសនា ប៉ុន្តែការដែលបុគ្គលណាម្នាក់បានប្រើប្រាស់វត្ថុទាំងនោះនៅក្នុងផ្ទះរបស់គាត់គឺមិនមែនមានន័យថា បុគ្គលនោះបានវិលត្រឡប់ទៅរកពហុទេពសាសនាវិញនោះទេ។ ខណៈពេលដែលពិតជាមានទំនៀមទម្លាប់មួយចំនួនដែលមានឫសគល់ទៅនឹងពហុទេពសាសនា ក៏ស្របពេលនឹងគ្នានោះដែរក៏នៅមានទំនៀមទម្លាប់ជាច្រើនផ្សេងទៀតដែលមានឫសគល់ដ៏ពិតទាក់ទង និងអត្ថន័យនៃពិធីបុណ្យណូអែល  ការប្រសូតនៃព្រះសង្គ្រោះសម្រាប់លោកីយ៍ទាំងមូលនៅភូមិបេថ្លេហិម។ គេប្រើប្រាស់កណ្តឹងក្នុងការគោះ ដើម្បីប្រកាសអំពីដំណឹងដ៏មានអំណរណាមួយ។ ការដុតទៀនគឺជាការរម្លឹកយើងថា ព្រះគ្រីស្ទគឺជាពន្លឺនៃលោកា (យ៉ូហាន ១:៤-៩)។ ផ្កាយដែលគេដាក់លើចុងដើមណូអែលគឺជាការរម្លឹកអំពីផ្កាយនៃភូមិបេថ្លេហិម ហើយការប្តូរកាដូគ្នាទៅវិញទៅមក គឺជាការរម្លឹកយើងអំពីការដែលពួកហោរាពីទិសខាងកើតបាន

ប្រទានអំណោយទៅកាន់ព្រះយេស៊ូវ ដែលជាអំណោយទានដ៏អស្ចារ្យបំផុតពីព្រះជាម្ចាស់ទៅកាន់មនុស្សលោក។

មានការជជែកវែកញែកគ្នាមួយទៀតដែលទាស់ទៅនឹងការប្រារព្ធពិធីបុណ្យណូអែល ជាពិសេសការមានដើមណូអែល គឺថាព្រះគម្ពីរហាមមិនឲ្យយកដើមឈើចូលមកក្នុងផ្ទះ ហើយតុបតែងវាទេ។ កណ្ឌគម្ពីរ យេរេមា ១០:១-១៦ គឺជាខគម្ពីរដែលគេតែងតែលើកយកមកប្រើប្រាស់ ដើម្បីប្រឆាំង ប៉ុន្តែខគម្ពីរមួយនេះកំពុងនិយាយសំដៅទៅលើការកាប់ដើមឈើ យកវាឆ្លាក់ទៅធ្វើជារូបព្រះទេតើ ហើយបន្ទាប់មកតុបតែងរូបព្រះនោះដោយប្រើប្រាស់មាសប្រាក់សម្រាប់ទុកជាគោលបំណងនៃការក្រាបចុះថ្វាយបង្គំពីមុខវា (អេសាយ ៤៤:៩-១៨)។ ដាច់ខាត! យើងមិនត្រូវដកខគម្ពីរនៅក្នុងកណ្ឌគម្ពីរយេរេមាយកមកប្រើប្រាស់ខុសបរិបទជាការជជែកវែកញែកគ្នាដ៏ត្រឹមត្រូវទាស់នឹងការមានដើមណូអែលនោះឡើយ។

គ្រីស្ទបរិស័ទ ដែល បាន ជ្រើស រើស មើលរំលង ការ ប្រារព្ធ ពិធី បុណ្យណូអែល ចង្អុលបង្ហាញទៅលើចំណុចពិតដែលថា ព្រះគម្ពីរមិនបានផ្តល់នូវថ្ងៃខែកំណើតរបស់ព្រះគ្រីស្ទទេ ដែលតាមពិតទៅនោះគឺជាចំណុចដ៏ពិតមែន។ ទំនងថ្ងៃទី២៥ ខែធ្នូ គឺមិនមែនជាពេលវេលានៅជិតពេលវេលាដែលព្រះយេស៊ូវបានប្រសូតផង ហើយភាគីទាំងពីរបានធ្វើការជជែកវែកញែកមួយនេះគឺត្រឹមត្រូវ មានចំណុចខ្លះស៊ីគ្នាទៅនឹងរដូវកាលនៅប្រទេសអ៊ីស្រាអែលទំនៀមទម្លាប់មួយចំនួននៃការឃ្វាលសត្វចៀមនៅរដូវត្រជាក់ នឹងកាលបរិច្ឆេទនៃការដែលសាសន៍រ៉ូមធ្វើការជំរឿនប្រជាជន។ គ្មានចំណុចណាមួយក្នុង

ចំណោមចំណុចទាំងអស់នោះដែលមិនមានបរិមាណនៃការប៉ាន់ស្មានខ្លះៗ នោះទេ ដែលចំណុចនេះនាំយើងឲ្យវិលត្រឡប់ទៅរកចំណុចពិតវិញដែលថា ព្រះគម្ពីរមិនបានប្រាប់យើងអំពីពេលវេលានៃពេលដែលព្រះយេស៊ូវប្រសូត នោះឡើយ។ មនុស្សមួយចំនួនយកចំណុចនេះមកធ្វើជាភស្តុតាងវិជ្ជមាន ដែលថា ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឲ្យយើងប្រារព្ធការប្រសូតរបស់ ទ្រង់ទេ ស្របពេលនោះដែរ ក៏នៅមានមនុស្សមួយចំនួនកាត់យល់ចំណុច ដែលថា ព្រះគម្ពីរមិនបានលើកឡើងគឺជាការគាំទ្រ។

គ្រីស្ទបរិស័ទមួយចំនួនបានអះអាងថា ដោយសារលោកីយ៍បានប្រារព្ធ ពិធីបុណ្យណូអែល—ទោះបើថា ឥឡូវនេះខាងនយោបាយលើកឡើងថា ប្រសិនបើចង់និយាយឲ្យត្រូវ នោះគួរហៅពិធីបុណ្យនេះថា «ថ្ងៃសម្រាក»—ដូច្នេះហើយគ្រីស្ទបរិស័ទគួរតែគេចចេញពីវាទៅ។ ប៉ុន្តែ ចំណុចជជែកវែកញែកមួយនេះគឺដូចគ្នា និងចំណុចជជែកវែកញែកដែលសាសនាខុសឆ្គង យកមកប្រើប្រាស់ ដើម្បីបដិសេធព្រះគ្រីស្ទទាំងមូល ក៏ដូចជាក្រុមខុសឆ្គង ជាច្រើនទៀតដែរ ឧទាហរណ៍ពួកសាក្សីយេហូវ៉ាដែលបដិសេធភាពជាព្រះ របស់ព្រះគ្រីស្ទ។ គ្រីស្ទបរិស័ទ ដែលប្រារព្ធពិធីបុណ្យណូអែលជាទូទៅចាត់ ទុកឱកាសនោះជាពេល ដើម្បីប្រកាសអំពីព្រះគ្រីស្ទថា «ព្រះអង្គគឺជាមូល ហេតុនៃការប្រារព្ធពិធីបុណ្យនេះ» ទៅកាន់ពិភពលោកទាំងមូល និងទៅកាន់ អស់អ្នកដែលជាប់ក្នុងអន្ទាក់នៃសាសនាខុសឆ្គង។

ដូចដែលយើងបានឃើញរួចហើយ មិនមានហេតុផលសមរម្យណា មួយចេញពីព្រះគម្ពីរក្នុងការហាមប្រាមមិនឲ្យប្រារព្ធពិធីបុណ្យណូអែលនោះ

ទេ។ ហើយស្របគ្នានោះដែរ ក៏មិនមានការបញ្ជាចេញពីព្រះគម្ពីរដែលតម្រូវឲ្យយើងប្រារព្ធពិធីបុណ្យនៅឯណាដែរ។ តាមពិតទៅ ជាចុងបញ្ចប់ ការប្រារព្ធ ឬក៏មិនប្រារព្ធពិធីបុណ្យណូអែលគឺជាការសម្រេចចិត្តផ្ទាល់ៗខ្លួនទេតើ។ មិនថាគ្រីស្ទបរិស័ទសម្រេចចិត្តបែបណាក៏ដោយ ទាក់ទងនឹងពិធីបុណ្យណូអែល ក៏ពួកគាត់មិនគួរប្រើប្រាស់ទស្សនៈផ្ទាល់ខ្លួនទុកជាការវ៉ៃផ្ចួលនរណាម្នាក់ចុះ ឬក៏រិះគន់នរណាម្នាក់បែបមិនត្រឹមត្រូវដែលជំទាស់នឹងទស្សនៈគាត់នោះឡើយ ហើយភាគីទាំងពីរនៃទស្សនៈនីមួយៗក៏មិនគួរប្រើប្រាស់ការសម្រេចចិត្តរបស់ខ្លួនទុកជាគ្រឿងបំពាក់ដែលជាសញ្ញានៃការផ្តល់កិត្តិយសដែលតម្កើងអំនួតអួតអាង ដើម្បីប្រារព្ធ ឬក៏មិនប្រារព្ធផងដែរ។ ដូចនៅក្នុងរាល់គ្រប់ចំណុចទាំងអស់ យើងអាចស្វែងរកប្រាជ្ញាពីព្រះអង្គដែលប្រទានឲ្យដ៏ទូលំទូលាយទៅកាន់អស់អ្នកដែលទូលសូមពីទ្រង់ (យ៉ាកុប ១:៥) ហើយទទួលយកគ្នាទៅវិញទៅមកក្នុងក្តីស្រឡាញ់ និងព្រះគុណបែបជាគ្រីស្ទបរិស័ទ មិនថាយើងកាន់ទស្សនៈមួយណាក៏ដោយដែលទាក់ទងនឹងបុណ្យណូអែល។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ ក្រុម Got Questions
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.gotquestions.org/Christian-Christmas.html ដោយមានការអនុញ្ញាត។

# ២ តើអ្វីទៅជាអត្ថន័យបុណ្យណូអែល?

តើអត្ថន័យបុណ្យណូអែលផ្តោតរំពឹងទៅលើកាដូ ដើមណូអែល ឬក៏ភ្លើងពណ៌ផ្សេងៗមែនឬ? មិនដូច្នេះទេ! យើងអាចរកអត្ថន័យឃើញនៅក្នុងអំណរនៃការដឹងថា ប្រវត្តិសាស្ត្រដែលធ្វើឲ្យមានការផ្លាស់ប្តូរទាក់ទងនឹងរឿងដែលព្រះគ្រីស្ទប្រសូតមកជាមនុស្ស គឺជារឿងពិត!

មានបុណ្យណូអែលមួយ ដែលពេលនោះខ្ញុំបានអានកាសែតនិពន្ធដោយអ្នកសារព័ត៌មានដែលគាត់កំពុងតែព្យាយាមស្វែងរកអត្ថន័យនៃបុណ្យណូអែល។ សេចក្តីសន្និដ្ឋានពីការស្វែងរករបស់គាត់ គឺគាត់បានឲ្យពិន្ទុយ៉ាងល្អបំផុតទៅលើចម្លើយរបស់ខ្លួនឯង ដោយបានលើកឡើងថា៖ “អត្ថន័យនៃបុណ្យណូអែលគឺមាននៅក្នុងចិត្តរបស់លោកអ្នក។ វាគឺជាអារម្មណ៍ដ៏កក់ក្តៅ

ជាអារម្មណ៍ដែលជះពន្លឺ ហើយលោកអ្នកក៏មិនអាចប្រើលុយទិញអត្ថន័យនេះបានទេ ហើយក៏មិនអាចយកអត្ថន័យនេះចេញពីបុគ្គលណាម្នាក់បានដែរ»។

នេះឯងជាគំនិតដ៏មានប្រជាប្រិយភាពទាក់ទងទៅនឹងបុណ្យណូអែលគឺថា អត្ថន័យគឺនៅក្នុងយើងផ្ទាល់។ យើងគ្រាន់តែត្រូវទទួលយកវាតែប៉ុណ្ណោះ។ តើអ្នកនោះមានន័យថា យើងគ្រាន់តែទាញយករបស់មកតុបតែង ហើយចាក់បទចម្រៀងដែលទាក់ទងនឹងបុណ្យណូអែលប៉ុណ្ណោះ ហើយរាប់ថានេះជាបុណ្យណូអែលឬ? តើយើងត្រូវតែមានដើមណូអែលឬ? ហើយតើយើងគួរតែមានខ្សែអំពូលភ្លើងភ្លឺភ្លឹបភ្លែតៗមួយខ្សែឬពីរខ្សែឬ? ឬក៏វាទាក់ទងទៅនឹងការដែលត្រូវមានកាដូឲ្យច្រើនជាងមុន? ឬក៏ទាល់តែយើងត្រូវតុបតែងគេហដ្ឋានឲ្យបានស្អាតជាងអ្នកដែលនៅជិតខាងយើងមែនឬ?

## ការវិលត្រឡប់ទៅចំណុចដើម

ដូច្នេះខ្ញុំក៏បានសម្រេចចិត្តអានរឿងទាក់ទងនឹងបុណ្យណូអែលនៅក្នុងព្រះគម្ពីរជាថ្មីម្តងទៀត។ ខ្ញុំចង់សិក្សាពីការឆ្លើយតបរបស់អ្នកគង្វាលដែលគាត់កំពុងតែធ្វើការនៅវេលាយប់នោះ ហើយពួកគាត់ជាមនុស្សដំបូងដែលទទួលបានដំណឹងទាក់ទងនឹងការប្រសូតរបស់ព្រះឱរសយេស៊ូវ។ ព្រះគម្ពីរបានប្រាប់ឲ្យយើងដឹងថា បន្ទាប់ពីពួកគេបានឃើញទ្រង់ នោះពួកគេក៏បានវិលត្រឡប់ទៅកាន់ហ្វូងចៀមរបស់ពួកគេវិញ “ទាំងសរសើរតម្កើងដល់ព្រះ ដោយព្រោះគ្រប់ទាំងការដែលគេបានឮ ហើយឃើញនោះ» (លូកា ២:៨-២០)។

សូមចងចាំថា អ្នកគង្វាលចៀមនៅសម័យកាលនោះ មិនសូវជាមាន

ភាពស្លូតបូត ឬមានសម្ដីទន់ភ្លន់ដូចដែលយើងបានឃើញនៅក្នុងរូបកាតណូអែលមួយចំនួននោះទេ។ តែពួកគាត់ក៏ទំនងជាមានភាពមាំមួន រឹងពឹងដែលនិយាយឲ្យខ្លីទៅ លោកអ្នកមិនគួរបបួលពួកគាត់មកវាយគ្នាឡើយ ព្រោះពួកគាត់ខ្លាំងៗ។ ពេលដែលព្រះគម្ពីរលើកឡើងថា ពួកគាត់បានថ្វាយសិរីល្អ ហើយសរសើរតម្កើងព្រះជាម្ចាស់ ការនោះគឺជាការពណ៌នាដែលស្រដៀងទៅនឹងការប្រកួតកីឡាវគ្គជម្រុះចោលមួយ ហើយនៅពេលដែលក្រុមដែលយើងគាំទ្រទទួលបានជ័យជម្នះ នោះយើងនឹងលោតរាំកញ្ឆែអបអរសាទរយ៉ាងកក្អាកកក្អាយទាំងស្រែកយ៉ាងខ្លាំងៗផង។ ហើយនោះឯងជាប្រភេទនៃការអបអរសាទរតែមួយគត់ដែលពួកអ្នកគង្វាលដឹងទាក់ទងនឹងការសរសើរតម្កើង។ និយាយរួមទៅ ពួកគេមានការរន្ធត់ញាប់ញ័រជាខ្លាំង!

ការប្រសូតរបស់ព្រះគ្រីស្ទបានផ្លាស់ប្ដូររាល់គ្រប់អ្វីៗទាំងអស់។ នោះឯងជាអ្វីដែលពួកអ្នកគង្វាលជាអ្នកដែលធ្វើការយ៉ាងនឿយហត់បានអបអរសាទរយ៉ាងរំភើបញាប់ញ័រក្រៃលែង! ព្រះឱរសអង្គមួយនោះ គឺជាភស្តុតាងដែលបង្ហាញថា ព្រះជាម្ចាស់ពិតជាបានស្រឡាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ «បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។

## អត្ថន័យដ៏ពិតនៃបុណ្យណូអែល

ព្រះឱរសនោះក៏បានធ្វើឲ្យយើងមានចម្ងល់ជាថ្មីម្ដងទៀតថា «តើអ្វីទៅជាអត្ថន័យនៃបុណ្យណូអែល?»។ ខ្ញុំជឿថា អត្ថន័យនៃបុណ្យណូអែលគឺ ការមានអំណរដ៏ជ្រាលជ្រៅដោយសារយើងដឹងយ៉ាងច្បាស់លាស់ថា រឿងនៃព្រះឱរសដែលជាព្រះគ្រីស្ទ គឺជារឿងដ៏ពិត ហើយមានពេញដោយសិរីល្អមែន។ នៅឆ្នាំនេះនឹងមានមនុស្សជាច្រើនប្រារព្ធធ្វើពិធីបុណ្យណូអែល ហើយពេលនោះពួកគាត់នឹងដូរកាដូគ្នាទៅវិញទៅមក ហើយនឹងរីករាយជាខ្លាំង។ ប៉ុន្តែពួកគេនឹងមិនដែលយល់ពីភាពស៊ីគ្នារវាងការប្រារព្ធ និងមូលហេតុដែលត្រូវប្រារព្ធពិធីបុណ្យណូអែលនោះឡើយ។ ពួកគាត់ប្រៀបដូចជាមនុស្សដែលទៅចូលរួមពិធីមង្គលការមួយដែលកំពុងតែអរសប្បាយយ៉ាងក្អាកក្អាយ ប៉ុន្តែពួកគាត់ទាំងនោះមិនដែលទាំងស្គាល់កូនក្រមុំ ឬក៏កូនកំលោះសោះឡើយ។

នេះហើយគឺជាភាពខុសគ្នារវាងអស់អ្នកដែលស្គាល់អត្ថន័យនៃបុណ្យណូអែលដ៏ពិត និងអ្នកដែលមិនបានស្គាល់អត្ថន័យនៃបុណ្យណូអែលនេះ។ ចំពោះអស់អ្នកណាដែលពិតជាស្គាល់ពីអត្ថន័យនៃបុណ្យណូអែលនេះ ទោះបើគេដកដើមណូអែល ដកភ្លើងពណ៌ ដកកាដូ ដកម្ហូបអាហារ និងដកបទចម្រៀងដែលទាក់ទងនឹងបុណ្យណូអែលចេញក៏ដោយ ក៏ពួកគាត់នឹងនៅតែមានអំណរនោះដដែល។ ពីព្រោះរឿងនៃការដែលព្រះបានយាងមកលើផែនដីក្នុងនាមជាព្រះឱរសជារឿងពិតប្រាកដ ហើយពួកគាត់ក៏បានស្គាល់ពីព្រះគ្រីស្ទផ្ទាល់ដែលទ្រង់បានប្រសូត ហើយធំនៅក្នុងស្នូកផងដែរ។

## តើព្រះឱរសដែលផ្ទំនៅក្នុងស្នូកនោះមានសារៈសំខាន់ខ្លាំងប៉ុណ្ណា?

តើលោកអ្នកស្គាល់ពីសារៈសំខាន់នៃការដែលព្រះឱរសផ្ទំនៅក្នុងស្នូកដែរឬទេ? ពួកទេវតាបានប្រាប់ទៅកាន់ពួកអ្នកគង្វាលថា «...ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសម្រាប់បណ្តាជនទាំងអស់គ្នា ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់» (លូកា ២:១០-១១)។ ព្រះឱរសនោះបានប្រសូតនៅភូមិបេថ្លេហិម ផ្ទំក្នុងស្នូក ទ្រង់ផ្ទាល់គឺជាព្រះ។ ការដែលព្រះរាជបុត្រារបស់ព្រះយាងមកយកកំណើតជាមនុស្ស នោះឯងគឺជាការដ៏អស្ចារ្យ។ ហើយ៣៣ឆ្នាំក្រោយមក ព្រះអង្គបានសុគតជំនួសយើង។ «ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រួបសង្រួមតែ១ នៅកណ្តាលព្រះនឹងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ ទ្រង់បានថ្វាយព្រះអង្គទ្រង់ ទុកជាថ្លៃលោះមនុស្សទាំងអស់» (១ធីម៉ូថេ ២:៥-៦)។ ព្រះយេស៊ូវបានយាងមកបង់ថ្លៃលោះនៃអំពើបាបរបស់យើងដែលយើងមិនអាចបង់បាន។

យញ្ញបូជានៅលើឈើឆ្កាងដោយការសុគតរបស់ទ្រង់បានបង់ថ្លៃលោះនូវរាល់អំពើបាបដែលលោកអ្នក ហើយនិងខ្ញុំបានប្រព្រឹត្ត ទាំងនៅអតីតកាលនិងនាពេលអនាគតផងដែរ។ «ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះនោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ» (២កូរិនថូស ៥:២១)។ ការដែលព្រះគ្រីស្ទរស់ឡើងវិញបីថ្ងៃក្រោយទ្រង់បានសុគតនោះ (លូកា ២៤) គឺជាអំណះអំណាងថា ព្រះវរបិតាបានទទួលថ្លៃលោះ។ ឥឡូវ

នេះ «...អ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ» (យ៉ូហាន ៣:១៨) ។

តើលោកអ្នកចង់ទទួលបានអត្ថន័យនៃបុណ្យណូអែលតាមរយៈការស្គាល់ព្រះគ្រីស្ទដែរឬទេ? តើលោកអ្នកចង់ទទួលបាននូវការអត់ទោស និងជីវិតអស់កល្បជានិច្ចដែលព្រះយេស៊ូវគ្រីស្ទបានយាងមកលើពិភពលោកនេះ ដើម្បីផ្តល់ជូនដល់លោកអ្នកដែរឬទេ? លោកអ្នកអាចលើកឡើងពីបំណងប្រាថ្នានៃដួងចិត្តរបស់លោកអ្នកដោយការជឿទុកចិត្តលើទ្រង់នៅឥឡូវនេះ។ បើលោកអ្នកមានបំណងចង់ស្គាល់ព្រះគ្រីស្ទ នោះសូមប្រើលំនាំនៃសេចក្តីអធិស្ឋានដូចខាងក្រោមនេះជាគំរូ៖

ឱ! ព្រះអម្ចាស់យេស៊ូវអើយ! ខ្ញុំចង់ស្គាល់ព្រះអង្គដោយផ្ទាល់។ ខ្ញុំសូមអរព្រះគុណដែលទ្រង់បានសុគតនៅលើឈើឆ្កាងជំនួសបាបរបស់ខ្ញុំ។ ខ្ញុំសូមបើកទ្វារដួងចិត្តរបស់ខ្ញុំទៅចំពោះព្រះអង្គ ហើយសូមអញ្ជើញព្រះអង្គយាងមកគង់នៅក្នុងដួងចិត្តខ្ញុំ ដើម្បីធ្វើជាព្រះសង្គ្រោះរបស់ខ្ញុំ។ ខ្ញុំសូមអរព្រះគុណដែលទ្រង់បានអត់ទោសគ្រប់ទាំងអំពើបាបរបស់ខ្ញុំ ហើយថែមទាំងប្រទានជីវិតដ៏អស់កល្បជានិច្ចឲ្យខ្ញុំទៀតផង។ សូមទ្រង់កែច្នៃខ្ញុំឲ្យបានទៅជាបុគ្គលដែលទ្រង់សព្វព្រះហឫទ័យចុះ។ អាម៉ែន!

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ ក្រុម Got Questions
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.gotquestions.org/Christmas-true-meaning.html ដោយមានការអនុញ្ញាត។

# ៣ ណូអែល ភាគទី៣...

«ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគតហើយឲ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបម្រើគ្រប់១ជីវិត ដោយខ្លាចស្លាប់ ឲ្យបានរួចចេញវិញ។» (ហេព្រើរ ២:១៤-១៥)

## គោលការណ៍សម្រាប់អានព្រះគម្ពីរ

ព្រះជាម្ចាស់បាននិពន្ធដំណើររឿងអំពីណូអែល ប៉ុន្តែភាគតិចណាស់ក្នុងចំណោមយើងបានចាប់អារម្មណ៍ហើយសួរថា តើហេតុអ្វីបានជាព្រះអង្គ

និពន្ធដំណើររឿងមួយនោះក្នុងរបៀបដែលទ្រង់បាននិពន្ធយ៉ាងដូច្នេះ។ នៅក្នុងកំណាត់ហេតុមួយនេះ លោកគ្រូ ចន ផាបភ័រ (John Piper) បានលើកឡើងនូវមូលហេតុ៤យ៉ាងទាក់ទងទៅ នឹងពិធីបុណ្យណូអែលចេញពីខគម្ពីរទាំងពីរខាងលើនេះ។

## មូលហេតុសម្រាប់ការប្រារព្ធពិធីបុណ្យណូអែល

១. ដោយសារយើងជាមនុស្ស ហេតុនេះហើយបានជាព្រះជាម្ចាស់បានយាងមកយកកំណើតជាមនុស្សដូចយើងដែរ (ហេព្រើរ ២:១៤)។

២. ដាច់ខាត! ព្រះយេស៊ូវពុំអាចស្លាប់បានឡើយ លុះត្រាតែទ្រង់បានក្លាយជាមនុស្សសិន (ហេព្រើរ ២:១៤)។

៣. ព្រះយេស៊ូវបានយាងមក ដើម្បីបំផ្លាញអារក្សសាតាំងចោលដែលមានអំណាចលើសេចក្ដីស្លាប់ (ហេព្រើរ ២:១៤)។

៤. ព្រះយេស៊ូវបានយាងមក ដើម្បីរំដោះយើងចេញពីទាសភាពដែលយើងជាប់ ព្រោះយើងខ្លាចស្លាប់ (ហេព្រើរ ២:១៥)។

## របៀបដែលព្រះយេស៊ូវបំផ្លាញអារក្សសាតាំង

១. ប្រាកដណាស់! ពាក្យថា “បំផ្លាញ” មិនមែនមានន័យថា បណ្ដាលឲ្យអារក្សសាតាំងលែងមានជីវិតតទៅទៀតនោះឡើយ។ សព្វថ្ងៃនេះ វានៅមានជីវិតរស់នៅឡើយទេតើ។ ទេ! តែព្រះយេស៊ូវបានកាច់បំបាក់ធ្មេងនៃអំណាចរបស់វាចោល (ហេព្រើរ ២:១៤)។

២. សាតាំងមានអំណាចលើសេចក្ដីស្លាប់ ព្រោះវាយកសេចក្ដីស្លាប់ធ្វើទ្វារទៅកាន់ស្ថាននរក មិនមែនស្ថានសួគ៌ទេ។ វាចោទលទោសយើងដោយពឹងអាងទៅលើបញ្ជី («សេចក្ដីដែលកត់ទុក») នៃអំពើបាបដែលយើងធ្លាប់ប្រព្រឹត្តកន្លងមក។

៣. ព្រះយេស៊ូវបានលុបបញ្ជីនៃបំណុលរបស់យើងចោល។ ការធ្វើបែបនេះបានដកហូតអាវុធរបស់សាតាំងចេញ ព្រោះវាគឺជាអ្នកប្រឆាំងនឹងយើងដ៏ខ្លាំងក្លា (កូឡូស ២:១៤)។

៤. ព្រះយេស៊ូវបានបំផ្លាញសាតាំង ដែលទ្រង់បានដកអាវុធរបស់វាចេញ ដែលអាវុធនោះគឺ បញ្ជីបំណុលនៃអំពើបាបរបស់យើង។ ឥឡូវនេះ យើងមានសេរីភាពរួចចេញពីការចោទលទោស សរុបសេចក្ដីទៅគឺចេញពីសេចក្ដីស្លាប់។

## សំណួរត្រិះរិះ

១. យ៉ាងហោចណាស់ មានមូលហេតុ៤យ៉ាងក្នុងកណ្ឌគម្ពីរ ហេព្រើរ ២:១៤-១៥ ដែលដំណើររឿងពិធីបុណ្យណូអែលបានកើតឡើងក្នុងរបៀបដែលវាបានកើតឡើង។ សូមព្យាយាមលើកឡើងនូវមូលហេតុឲ្យបានច្រើនតាមដែលលោកអ្នកអាចរកបាន។

២. សូមពិនិត្យមើលកណ្ឌគម្ពីរ កូឡូស ២:១៣-១៥។ តើខគម្ពីរនោះជួយឲ្យលោកអ្នកយល់ពីអត្ថន័យនៃពាក្យ «បំផ្លាញ» ទាក់ទងនឹងការដែលព្រះយេស៊ូវបានធ្វើទៅកាន់សាតាំងយ៉ាងដូចម្ដេច (ហេព្រើរ ២:១៤)?

៣. យោងតាមអ្វីដែលលោកអ្នកបានសិក្សា តើមានការអនុវត្តអ្វីខ្លះទាក់ទងទៅនឹងរបៀបដែលលោកអ្នកនឹងប្រារព្ធពិធីបុណ្យណូអែលនៅឆ្នាំនេះ?

យើងអាចនិយាយទៅកាន់គ្នាទៅវិញទៅមកថា "រីករាយថ្ងៃបុណ្យណូអែល" ពីព្រោះយើងបានមានសេរីភាពចេញពីទាសភាពដ៏តក់ស្លុតនៃអំពើបាប និងសេចក្តីនោះរួចហើយ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា និងលោក ទេព រ៉ូ
កែសម្រួលដោយ៖ លោកស្រី ឡូញ ណារ៉ុង, លោក ម៉េង មនោ, លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/labs/why-christmas
ដោយមានការអនុញ្ញាត។

# ៤ ព្រះបាន យាងចុះមក

ភាពរសើបរសាវនៃរដូវកាលបុណ្យណូអែល មានអំណាចយ៉ាងចំឡែកមកលើយើង សូម្បីតែចំពោះអ្នកមិនជឿ និងលោកីយ៍ទាំងមូល។ រដូវកាលនេះហាក់បីដូចជាមានភាពទាក់ទាញឲ្យយើងលង់នៅក្នុង «វេទមន្ត» នៃការប្រារព្ធពិធី។

តើហេតុអ្វីបានរដូវកាលណូអែលមានការទាក់ទាញបែបនេះ សូម្បីតែនៅក្នុងសង្គមដែលចង់ដកព្រះគ្រីស្ទចេញពីចំណុចស្នូល? ភាពទាក់ទាញនៃវេទមន្តដ៏ពិតនៃរដូវកាលបុណ្យណូអែលគឺមិនមែនផ្តោតលើកាដូ របស់លេ្អៗ តុក្កតាថ្មីៗ ឬប្រពៃណីដែលយើងស្គាល់នោះទេ។ ចំណុចស្នូលនៃបុណ្យណូអែល ហើយថែមទាំងខ្សឹបខ្សៀវទៅកាន់វិញ្ញាណដែលព្យាយាម «បង្ខាំង

សេចក្តីពិត» (រ៉ូម ១:១៨)] គឺត្រង់ចំណុចដ៏គួរឲ្យស្ញប់ស្ញែង និងអស្ចារ្យក្នុងប្រវត្តិសាស្ត្រពិភពលោក៖ ព្រះផ្ទាល់បានយាងមកយកកំណើតជាមនុស្សដូចយើងដែរ។ គឺព្រះត្រៃឯកនៃផែនដីយើងនេះ ហើយយើងជាស្នាព្រះហស្តដ៏ល្អប្រពៃក្នុងចំណោមរបស់សព្វសារពើដែលទ្រង់បានបង្កើតមក ពោលគឺទ្រង់បានយាងមកយកកំណើតជាមនុស្ស មិនមែនគ្រាន់តែជាការសម្តែងឲ្យល្អមើលតែប៉ុណ្ណោះទេ ប៉ុន្តែគឺដើម្បីសង្គ្រោះយើង។

រដូវកាលបុណ្យណូអែលគឺជារដូវកាលអធម្មជាតិ។ ហើយសង្គមរបស់យើងដែលគ្រាន់តែផ្តោតទៅលើអ្វីៗដែលមើលឃើញនឹងភ្នែក ក៏ពួកគាត់កំពុងតែស្រេកឃ្លានយ៉ាងខ្លាំងសម្រាប់អ្វីមួយផ្សេងទៀតដែលលើសពីធម្មជាតិ ទោះបើពួកគាត់មិនងាយទទួលស្គាល់ ឬក៏មិនដឹងច្បាស់អំពីមូលហេតុក៏ដោយ។ រដូវកាលបុណ្យណូអែលរំញោចលើអ្វីមួយដែលរឿងអាថ៌កំបាំងក្នុងព្រលឹងយើងមាន ហើយថែមទាំងដាក់ស្នេហ៍លើយើងផងដែរ សូម្បីតែពេលដែលគំនិតគិតគូររបស់យើងគ្មានការស៊ីគ្នាដ៏ជាក់លាក់ដែលមិនទទួលជឿក៏ដោយ។

## ព្រះអង្គបានយាងចុះមកពីស្ថានសួគ៌

ចំពោះអស់អ្នកក្នុងចំណោមយើង ដែលសារភាពដោយមានអំណរថា ព្រះគ្រីស្ទជាចំណុចស្នូលនៃពិធីបុណ្យណូអែលជាព្រះអម្ចាស់នៃយើង ជាព្រះសង្គ្រោះ និងជាទ្រព្យសម្បត្តិដ៏មានតម្លៃមហិមា យើងដឹងពីមូលហេតុដែលធ្វើបុណ្យណូអែលមានភាពរីករាយ ពីព្រោះក្នុងចំណុចស្នូលគឺខ្លឹមសារនៃភាពអធម្មជាតិ៖ ព្រះផ្ទាល់បានយាងមកក្នុងពិភពយើង។ ក្នុងរដូវកាល

បុណ្យណូអែលព្រះបាន «យាងចុះមក» (លោកុប្បត្តិ ១១:៥) មិនមែន គ្រាន់តែចុះមកទតមើលគំនរនៃអំពើបាបដែលមនុស្សយើងបានសងឡើង ដូចជាប៉មបាបិលនោះទេ ហើយក៏មិនមែនយាងមក ដើម្បីថ្កោលទោសដ៏ យុត្តិធម៌ពីខាងក្រៅនោះដែរ ប៉ុន្តែដើម្បីយកកំណើតជាមនុស្ស ព្រមទាំងផ្តល់នូវ សេចក្ដីមេត្តាករុណាចេញពីក្នុងមកវិញ។

ភាពរុងរឿងនៃបុណ្យណូអែលគឺមិនមែនជាទីសម្គាល់ត្រង់ថា មេដឹកនាំ សាសនាម្នាក់បានប្រសូតនោះឡើយ ប៉ុន្តែគឺជាការប្រារព្ធនៃការរង់ចាំយ៉ាង យូរពីការដែលព្រះផ្ទាល់បានយាងចុះមក—គឺជាការយាងចុះមកដែល ព្រះជាម្ចាស់បានដាក់នៅក្នុងព្រលឹងវិញ្ញាណរបស់យើងតាំងពីដើមមកម្ល៉េះ។ «ឱ! បេថ្លេហិម-អេប្រាតាអើយ...នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នក នោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបាន ចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក» (មីកា ៥:២)។

ចូរឲ្យផ្ទៃមេឃមានសេចក្តីអំណរ ហើយឲ្យផែនដីបានរីករាយឡើង។
ឲ្យសមុទ្រលាន់ឮរំពងឡើង ព្រមទាំងរបស់សព្វសារពើនៅក្នុងនោះដែរ!
ចូរឲ្យស្រែចំការ នឹងរបស់ទាំងប៉ុន្មាន ដែលមាននៅទីនោះបានសប្បាយ ឡើងយ៉ាងក្រៃលែង
នោះអស់ទាំងដើមឈើនៅព្រៃនឹងច្រៀង ដោយអំណរដែរ
គឺនៅចំពោះព្រះយេហូវ៉ា ដ្បិតទ្រង់យាងមក
គឺទ្រង់យាងមក ដើម្បីជំនុំជម្រះផែនដី។
ទ្រង់នឹងជំនុំជម្រះលោកីយ៍ ដោយសេចក្តីសុចរិត

ព្រមទាំងសាសន៍ទាំងប៉ុន្មាន ដោយសេចក្ដីពិតត្រង់របស់ទ្រង់។
(ទំនុកតម្កើង ៩៦:១១-១៣)

អ្វីដែលព្រះជាម្ចាស់បានបើកសម្ដែងដែលគួរឲ្យភ្ញាក់ផ្អើលនៅរដូវកាលណូអែលដំបូងគឺត្រង់ថា នៅចុងបញ្ចប់ព្រះអង្គផ្ទាល់បានយាងចុះមក មិនមែននៅក្នុងពពក ឬក៏នៅក្នុងខ្យល់ព្យុះ ឬក៏នៅក្នុងភ្លើង ឬក៏នៅក្នុងការរំញ្ជួយដី ឬក៏សូម្បីតែនៅក្នុងសំឡេងដ៏ស្រទន់ ហើយស្ងៀមស្ងាត់នោះទេ ប៉ុន្ដែទ្រង់បានយាងមកនៅក្នុងសណ្ឋានដ៏ពេញទីនៃរាល់អ្វីៗដែលទ្រង់បានបង្កើតមកគឺ៖ ជាមនុស្ស។ ព្រះអង្គបានយាងចុះមកក្នុងនាមដូចយើងម្នាក់ ហើយក្នុងការធ្វើបែបនោះព្រះអង្គបានលើកស្ទួយពូជអំបូរយើង។ ព្រះអង្គមិនបានយាងចុះមកជាសត្វបក្សាបក្សីនៅលើអាកាស ឬក៏ដូចសត្វតិរច្ឆាននៅក្នុងព្រៃ ឬក៏មច្ឆាដ៏ខ្លាំងក្លានៅក្នុងសមុទ្រនោះដែរ។ ហើយអ្វីដែលគួរឲ្យកាន់តែភ្ញាក់ផ្អើលថែមទៀតគឺថា ព្រះអង្គមិនបានយាងមកដូចជាសត្វសិង្ហដែលចេះនិយាយមួយនោះទេ តែទ្រង់បានយាងមកនៅក្នុងសណ្ឋានជាមនុស្សយ៉ាងពេញទី! បុណ្យណូអែលគឺជាការកត់សម្គាល់អំពីការដែលទ្រង់បាន “ប្រសូតមកមានរូបជាមនុស្ស”—គឺព្រះអង្គផ្ទាល់ដែលបានបង្កើត ហើយទ្រង់ក៏ថែមទាំងមានព្រះទ័យអត់ធ្មត់យ៉ាងក្រៃលែង ដែលឥឡូវនេះ “ឃើញទ្រង់មានភាពជាមនុស្ស” ទោះបើភាពជាមនុស្សយើងមានភាពគួរស្អប់ខ្ពើមក៏ដោយ (ភីលីព ២:៧-៨)។

## ព្រះអង្គបានយាងចុះមកដើម្បីធ្វើជាបាវបម្រើ

យើងមានការងឿងឆ្ងល់គ្រប់គ្រាន់ល្មមហើយត្រង់ថា ទ្រង់បាន «យាងចុះមក» ប៉ុន្តែនៅពេលដែលទ្រង់បានធ្វើដូច្នោះ គឺទ្រង់មិនបានយាងចុះមកជាមនុស្សដែលពេញដោយសិរីរុងរឿង ភាពស្រណុកសុខស្រួល និងភាពថ្លៃថ្នូរនោះទេ តែ «ទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបម្រើ» (ភីលីព ២:៧)។ ព្រះអង្គមិនគ្រាន់តែយាងមកក្នុងនាមដូចជាអ្វីដែលទ្រង់បានបង្កើតនោះឡើយ ប៉ុន្តែទ្រង់បានយាងចុះមកដោយមានភាពក្រីក្រ ភាពទន់ខ្សោយ និងការបន្ទាបខ្លួនទៀតផង។ ទ្រង់បានយាងមកដូចនេះ៖

«បានជាទ្រង់ក្រោកពីសោយឡើងដោះព្រះពស្ត្រចេញ រួចយកក្រមាមកក្រវាត់អង្គ ក្រោយនោះទ្រង់ចាក់ទឹកក្នុងចានក្លាំ ចាប់តាំងលាងជើងពួកសិស្ស ហើយយកក្រមាដែលទ្រង់ក្រវាត់នោះមកជូត» (យ៉ូហាន ១៣:៤-៥)។

ក្នុងរយៈពេលដ៏ខ្លីមួយ នៅលើភ្នំដែលទ្រង់បានផ្លាស់ប្រែ មានពួកសិស្សទ្រង់បីនាក់បានឃើញបន្តិចបន្តួចនៃសិរីល្អ នៃភាពជាព្រះ និងភាពជាមនុស្សរបស់ទ្រង់ នោះឯងគឺជាអ្វីដែលទ្រង់បានកំណត់ទុកមកហើយ។ «រួចទ្រង់បានផ្លាស់ប្រែនៅមុខអ្នកទាំងនោះ ព្រះភក្ត្រទ្រង់បានភ្លឺដូចព្រះអាទិត្យ ហើយព្រះពស្ត្រទ្រង់ក៏ត្រឡប់ជាសដូចពន្លឺ» (ម៉ាថាយ ១៧:២) ។ ប៉ុន្តែ ព្រះយេស៊ូវដែលពួកគេស្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ នៅលើគ្រប់ច្រកល្ហក់ស្រុកកាលីឡេ គឺមិនមែនជាអ្នកមានឋានៈខ្ពង់ខ្ពស់ឡើយ។ «ព្រះយេស៊ូវមានបន្ទូលតបថា

កញ្ច្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសម្បុកដែរ តែកូនមនុស្ស គ្មានកន្លែងណានឹងកើយក្បាលទេ» (លូកា ៩:៥៨) ។ ពួកសាវ័ករបស់ទ្រង់ បានឃើញពីការនេះជាក់នឹងភ្នែក «ដ្បិតកូនមនុស្សក៏បានមក មិនមែនឲ្យគេ បម្រើដែរ គឺដើម្បីនឹងបម្រើគេវិញ» (ម៉ាកុស ១០:៤៥)។

## ព្រះអង្គបានយាងមកដើម្បីសុគត

ព្រះអង្គបានពង្រីកការបម្រើឲ្យកាន់តែស៊ីជម្រៅលើសពីភាពរអាក់រអួលនៃ ជីវិត ពោលគឺទ្រង់បានធ្វើជាយញ្ញបូជាដោយលះបង់ព្រះជន្មព្រះអង្គផ្ទាល់ ទោះបើនោះគឺជាយញ្ញបូជាចុងក្រោយក៏ដោយ។ ព្រះអង្គមិនមែនគ្រាន់តែ យាងមក ដើម្បីបម្រើនោះទេ ប៉ុន្តែដើម្បី «នឹងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្ស ជាច្រើនផង» (ម៉ាកុស ១០:៤៥)។

ការលាងជើងពួកសាវ័កគឺគ្រាន់តែជាផ្នែកនៃរឿងមួយតែប៉ុណ្ណោះ។ ពិត ណាស់! រឿងមួយនោះគឺពិតជាពិបាកបំភ្លេចចោលមែន ប៉ុន្តែរឿងមួយនេះគឺ គ្រាន់តែជាការភ្លក់រសជាតិដ៏តិចតួចមួយប៉ុណ្ណោះទាក់ទងនឹងព័ន្ធកិច្ចផ្សេងៗ ទៀតរបស់ទ្រង់។ រឿងមួយទៀតគឺថា ទ្រង់បានក្រោកពីសោយឡើង បាន នាំពួកសិស្សចេញទៅឯសួនច្បាររង់ចាំដោយមានការឈឺចាប់ ពេលពួកគេ មកចាប់ទ្រង់ ហើយទ្រង់បានធ្វើដំណើរតែឯងលើវិថីពេញទៅដោយការ ឈឺចាប់នៃការលាងជើងបានរំពឹងទុកៈ «បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូល ស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង» (ភីលីព ២:៨)។

## ព្រះអង្គបានយាងមកដើម្បីរំដោះរាស្ត្រទ្រង់

ប៉ុន្តែ នេះមិនមែនជាការយាងចុះចេញពីស្ថានសួគ៌ដ៏សាមញ្ញប៉ុណ្ណោះទេ គឺជាបាវបម្រើរហូតដល់សុគត។ នេះគឺជាការយាងចុះមកដោយមានគោលបំណង។ នេះគឺជាការបន្ទាបខ្លួនក្នុងបេសកកម្ម។ ការសុគតដែលព្រះអង្គបានយាងមក ដើម្បីសុគតគឺមិនមែនជាព្រឹត្តិការណ៍ដ៏ចៃដន្យក្នុងប្រវត្តិសាស្ត្រឡើយ។ ទ្រង់បានយាងមកសុគត ហើយមានព្រះជន្មរស់ឡើងវិញ។ វិសាលភាពនៃការថ្វាយយញ្ញបូជាចុងក្រោយរបស់ទ្រង់បានធួននឹងវិសាលភាពនៃការបះបោររបស់រាស្ត្រទ្រង់ ហើយការធួននោះក៏លើសជាងការបះបោរនោះទៀតផង។ ហើយតាមរយៈការធ្វើបែបនេះ ព្រះអង្គបានបង្ហាញយើងនូវជម្រៅចិត្តនៃក្តីស្រឡាញ់របស់ទ្រង់ផ្ទាល់ ហើយនិងរបស់ព្រះវរបិតាដែរ។ «តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង» (រ៉ូម ៥:៨)។

ភាពទាក់ទាញចេញពីរដូវការបុណ្យណូអែល គឺមិនមែនគ្រាន់តែក្នុងចំណុចថា ព្រះអង្គផ្ទាល់បានយាងចេញពីស្ថានសួគ៌មកយកកំណើតជាមនុស្សនោះទេ ហើយក៏រឹតតែមិនមែនត្រង់ថា ទ្រង់បានបន្ទាបអង្គខ្លួនផ្ទាល់ក្នុងនាមជាបាវបម្រើ ដើម្បីបំពេញនូវតម្រូវការរបស់អ្នកដទៃឡើយ។ ហើយក៏ថែមទាំងមិនមែនត្រង់ថា ទ្រង់យាងមកដើម្បីសុគត ឬដើម្បីបើកសម្តែងព័ន្ធកិច្ចរបស់ទ្រង់រហូតដល់ថ្នាក់ទ្រង់សុគតទៀតដែរ។ ភាពទាក់ទាញគឺត្រង់ថា ព្រះអង្គបានយាងចុះមក ហើយបានសម្រេចការទាំងអស់នោះ ដើម្បីរំដោះយើង។

នោះឯងគឺជាក្តីសន្យានៃសាររបស់ព្រះជាម្ចាស់បានលើកឡើង ចាប់តាំងពីពេលប្រកាសៈ «ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប» (ម៉ាថាយ ១:២១)។

ព្រះអង្គយាងចុះមករំដោះយើងចេញពីអំពើបាប និងដើម្បីស្តារយើងទៅកាន់អំណរចុងក្រោយដែលទ្រង់បានបង្កើតយើងឲ្យមានៈ គឺដើម្បីឲ្យស្គាល់ទ្រង់ ហើយឲ្យមានអំណរក្នុងទ្រង់។ ព្រះអង្គបានយាងមក ដើម្បីផ្សះផ្សាយើង «ឲ្យជានឹងអង្គទ្រង់» (កូឡុស ១:២០)។ ព្រះអង្គមិនបានយាងមកដើម្បីជំរុញឲ្យយើងយករដូវកាលបុណ្យណូអែលមកធ្វើជាមុខរបររកស៊ីលក់ដូរទេ ប៉ុន្តែ «ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ» (១ពេត្រុស ៣:១៨)។

ចំណាំៈ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ David Mathis
បកប្រែដោយៈ លោក ឈាង បូរ៉ា និងលោក ទេព រ៉ូ
កែសម្រួលដោយៈ លោកស្រី ឡូញ ណារ៉ុង, លោក ម៉េង មនោ, លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/articles/god-came-down ដោយមានការអនុញ្ញាត។

# ៥ ការយាងមក យកកំណើត ជាមនុស្ស

**ចំណុច១០យ៉ាងដែលលោកអ្នកគួរដឹង**

ចំណុចស្នូលនៃជំនឿគ្រីស្ទបរិស័ទ និងដំណឹងល្អ គឺបុគ្គល និងការសម្រេចព្រះហឫទ័យរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ក្រៅពីការដែល “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម” (យ៉ូហាន ១:១៤) និងការដែលព្រះរាជបុត្រាបានយាងមកយកកំណើតជាមនុស្ស រួចមានព្រះជន្មគង់នៅ និងសុគតជំនួសយើងក្នុងនាមជាព្រះអង្គសង្គ្រោះ នោះគ្មានសេចក្តីសង្គ្រោះណាផ្សេងឡើយ។ ក្រៅពីការដែលព្រះរាជបុត្រាដ៏នៅអស់កល្បជានិច្ចបានយាងមកយកកំណើតជាមនុស្ស ហើយធ្វើជាអ្នកតំណាងនៃការតាំងសញ្ញាថ្មី នោះនឹងគ្មានសេចក្តីសង្គ្រោះណាផ្សេងសម្រាប់លោកីយ៍នេះឡើយ។

ការដែលយើងគិតឲ្យកាន់តែស៊ីជម្រៅអំពីការយាងមករបស់ព្រះអម្ចាស់ គឺជាការដ៏ល្អណាស់។ ខាងក្រោមនេះរៀបរាប់ពីចំណុច១០យ៉ាងដែលយើងគួរយល់៖

## ១. ព្រះរាជបុត្រាដ៏នៅអស់កល្បជានិច្ចជាបុគ្គលផ្ទាល់ដែលសកម្មក្នុងការយាងមកយកកំណើត

កណ្ឌគម្ពីរ យ៉ូហាន ១:១៤ បានលើកឡើងយ៉ាងច្បាស់ថា “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម”។ បើនិយាយឲ្យចំទៅ ព្រះរាជបុត្រាដ៏អស់កល្បជានិច្ច គឺជាអង្គដែលបានយាងមកយកកំណើតជាមនុស្ស មិនមែនក្នុងលក្ខណៈជាព្រះនោះទេ។ ព្រះរាជបុត្រាដែលមានទំនាក់ទំនងជាមួយព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ បានសព្វព្រះហឫទ័យបន្ទាបអង្គទ្រង់ ហើយជ្រើសរើសយកភាពជាមនុស្សដោយស្ដាប់បង្គាប់ព្រះវរបិតា និងសម្រាប់ជាប្រយោជន៍នៃដំណឹងល្អរបស់យើង (ភីលីព ២:៦-៨)។

## ២. ក្នុងនាមជាព្រះរាជបុត្រា ជាបុគ្គលទីពីរនៃព្រះត្រៃឯក ព្រះយេស៊ូវ «ទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ [ជាម្ចាស់] ហើយជារូបភាពនៃអង្គទ្រង់» ដូច្នេះទ្រង់ជាព្រះ១០០%

ព្រះយេស៊ូវមានលក្ខណៈជាព្រះ ១០០% ដូចជាព្រះជាម្ចាស់ និងព្រះវិញ្ញាណបរិសុទ្ធដែរ។ ក្នុងនាមជារូបអង្គផ្ទាល់នៃព្រះវរបិតា (កូឡុស ១:១៥; ហេព្រើរ ១:៣) ព្រះរាជបុត្រា គឺជាព្រះ១០០%។ គ្រប់ភាពល្អឥតខ្ចោះ និង

លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ក៏ជារបស់ព្រះគ្រីស្ទដែរ ដ្បិតទ្រង់ជាព្រះរាជបុត្រា (កូឡូស ២:៩)។ ក្នុងនាមជាព្រះរាជបុត្រា ព្រះយេស៊ូវក៏មានចំណែកជាព្រះក្នុងការគ្រងរាជ្យ ការទទួលបានការថ្វាយបង្គំ និងធ្វើអ្វីៗក្នុងនាមជាព្រះរាជបុត្រាដែរ (ទំនុកដំកើង ១១០:១; អេភេសូរ ១:២២; ភីលីព ២:៩-១១; កូឡូស ១:១៥-១៧; ហេព្រើរ ១:២-៣; វិវរណៈ ៥:១១-១២)។

## ៣. ក្នុងនាមជាព្រះដ៏ជាព្រះរាជបុត្រា ព្រះយេស៊ូវបានមានព្រះជន្មគង់នៅតាំងពីអស់កល្បរៀងមកម្ល៉េះក្នុងទំនាក់ទំនងជាមួយព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ ហើយឥឡូវនេះយើងមើលឃើញពីសិរីល្អនោះយ៉ាងច្បាស់តាមរយៈការយាងមកយកកំណើតជាមនុស្ស

ចំណុចនេះស៊ីសង្វាក់គ្នាឥតខ្ចោះដែលព្រះរាជបុត្រាផ្ទាល់ (ដែលត្រូវបានចាត់មកពីព្រះវរបិតា និងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ) បានយាងមកយកកំណើតជាមនុស្ស ជាជាងព្រះវរបិតា ឬក៏ព្រះវិញ្ញាណបរិសុទ្ធ (យ៉ូហាន ១:១-២, ១៤, ១៨)។ ក្នុងការយាងមកយកកំណើតជាមនុស្ស ព្រះរាជបុត្រាបានបង្ហាញពីទំនាក់ទំនងនៃភាពជាព្រះដោយពឹងលើព្រះវរបិតា ហើយអ្វីៗទាំងអស់ដែលទ្រង់ធ្វើ គឺទ្រង់បានធ្វើដោយពឹងលើទំនាក់ទំនងជាមួយព្រះវរបិតាតាមរយៈព្រះវិញ្ញាណបរិសុទ្ធ (យ៉ូហាន ៥:១៩-៣០; ម៉ាកុស ១:១២; លូកា ៤:១-២១)។ តាំងពីអស់កល្បរៀងមក និងក្នុងការយាងមកយកកំណើតជាមនុស្ស គឺព្រះរាជបុត្រាមិនដែលធ្វើអ្វីមួយដោយពឹងតែលើរូបអង្គទ្រង់ផ្ទាល់

នោះទេ ប៉ុន្តែទ្រង់តែងតែធ្វើអ្វីៗដោយពឹងលើទំនាក់ទំនងដែលមិនអាចបែកគ្នាបានជាមួយព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ។

## ៤. ការយាងមកយកកំណើតជាមនុស្សគឺជាការបន្ថែម មិនមែនជាការដកចេញនោះទេ

ក្នុងការយាងមកយកកំណើតជាមនុស្ស ព្រះរាជបុត្រាដ៏គង់នៅអស់កល្បជានិច្ចដែលមានលក្ខណៈជាព្រះ មិនបានផ្លាស់ប្រែ ឬក៏បោះបង់ចោលភាពជាព្រះរបស់ទ្រង់ឡើយ។ តែផ្ទុយទៅវិញ ទ្រង់បានបន្ថែមលក្ខណៈថ្មីមួយទៀតលើរូបអង្គទ្រង់ គឺភាពជាមនុស្សដែលមានរួមបញ្ចូលទាំងរូបកាយ និងព្រលឹង (ភីលីព ២:៦-៨)។ ជាលទ្ធផល ព្រះយេស៊ូវដ៏ជាព្រះរាជបុត្រាគឺជាបុគ្គលតែមួយគត់ ដែលទ្រង់មានលក្ខណៈពីរយ៉ាងបូកជាមួយគ្នា ពោលគឺជាព្រះ១០០% និងជាមនុស្ស១០០%។

## ៥. ភាពជាមនុស្សដែលព្រះរាជបុត្រាដ៏ជាព្រះបានទទួលយក បានធ្វើឲ្យទ្រង់មានភាពជាមនុស្ស១០០% ប៉ុន្តែទ្រង់គ្មានអំពើបាបទេ

លក្ខណៈជាមនុស្សរបស់ព្រះយេស៊ូវមិនបានធ្លាក់ក្នុងអំពើបាបនោះទេ ហើយបាបក៏មិនមានឥទ្ធិពលលើទ្រង់ដែរ។ ព្រះយេស៊ូវមិនមានលក្ខណៈដូចយើង ដែលតែងតែចង់បះបោរនឹងព្រះជាម្ចាស់នោះទេ។ ព្រះយេស៊ូវបានដកបទពិសោធន៍ផ្ទាល់ក្នុងការរស់នៅលើផែនដីដែលបានធ្លាក់ក្នុងអំពើបាប

ប៉ុន្តែទ្រង់គ្មានចំណែកក្នុងពិរុទ្ធភាព ឬក៏ការបែកពីព្រះជាម្ចាស់ដូចដែលលោកអ័ដាមបានបន្សល់ទុកឲ្យមនុស្សម្នានោះឡើយ។ តាមពិតទៅ ព្រះយេស៊ូវមិនដែលបានប្រព្រឹត្តអំពើបាបសោះឡើយ ហើយទ្រង់ក៏មិនអាចប្រព្រឹត្តបាបបានដែរ (ម៉ាថាយ ៣:១៥; យ៉ូហាន ៨:៤៦; ហេព្រើរ ៤:១៥; ៧:២៦; ១ពេត្រុស ១:១៩)។ ទោះបើទ្រង់បានជួបប្រទះនឹងសេចក្តីល្បួងដូចយើងក៏ដោយ ក៏ទ្រង់នៅតែស្តាប់បង្គាប់ព្រះជាម្ចាស់បានយ៉ាងគ្រប់លក្ខណ៍ដដែល គឺទ្រង់បានស្តាប់បង្គាប់រហូតដល់សុគត ដើម្បីធ្វើជាអ្នកកណ្តាលនៃការតាំងសញ្ញាសម្រាប់យើង ហើយតាមរយៈចំណុចនោះ ទ្រង់បានសម្រេចការសង្គ្រោះរបស់យើងក្នុងនាមទ្រង់ជាមនុស្ស (១ធីម៉ូថេ ២:៥; ហេព្រើរ ៥:៥-១០)។

## ៦. ការដែលស្ត្រីព្រហ្មចារីមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាការដ៏អស្ចារ្យអំពីការដែលព្រះយេស៊ូវយាងមកយកកំណើតជាមនុស្ស

ការយាងមកយកកំណើតជាមនុស្ស គឺជារឿងអធិធម្មជាតិ ហើយក៏ជាការបង្ហាញពីអធិបតេយ្យភាព និងព្រះគុណនៃព្រះត្រៃឯក ក្នុងការដែលទ្រង់ចាប់ផ្តើមសង្គ្រោះរាស្ត្ររបស់ទ្រង់ដែរ (ម៉ាថាយ ១:១-២៥; លូកា ១:២៦-៣៨)។ ការដែលស្ត្រីព្រហ្មចារីមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាពេលវេលា និងជាយានដែលព្រះដ៏ជាព្រះរាជបុត្រាបានយកភាពជាមនុស្សមកបន្ថែមលើរូបអង្គទ្រង់ផ្ទាល់។ តាមរយៈការដែលស្ត្រីព្រហ្មចារីមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ ព្រះត្រៃឯកបានបង្កើតលក្ខណៈជាមនុស្សថ្មីសម្រាប់ព្រះ

រាជបុត្រា ហើយជាលទ្ធផល៖ នៅក្នុងព្រះគ្រីស្ទ យើងពិតជាបានជួបព្រះមុខទល់នឹងមុខ មិនមែនក្នុងលក្ខណៈដែលទ្រង់សណ្ឋិត ឬក៏គ្របបាំងដោយស្រមោលមនុស្សទេ ប៉ុន្តែគឺក្នុងសិរីល្អដ៏ពេញលេញបំផុត។ ទោះបើយើងឃើញព្រះគ្រីស្ទក្នុងលក្ខណៈជាមនុស្សក៏ដោយ ក៏ទ្រង់នៅតែមានលក្ខណៈលើសពីនោះដែរ គឺទ្រង់ជាព្រះអម្ចាស់ ជាព្រះដ៏ជាព្រះរាជបុត្រា ដែលបានបន្ទាបអង្គទ្រង់ ហើយបានសម្តែងសិរីល្អរបស់ទ្រង់តាមរយៈការយាងមកយកកំណើតជាមនុស្ស ហើយគង់នៅជាមួយយើង។

## ៧. ចាប់តាំងពីពេលដែលព្រះយេស៊ូវបានយាងមកចាប់កំណើតក្នុងផ្ទៃមក ទ្រង់បានដាក់កំណត់លើភាពជាព្រះរបស់ទ្រង់ ដោយទ្រង់មិនបានប្រើលក្ខណៈជាព្រះនោះ លើសពីអ្វីដែលភាពជាមនុស្សអនុញ្ញាតឲ្យប្រើឡើយ

លទ្ធផលនៃការយាងមកយកកំណើតជាមនុស្ស បានបណ្តាលឲ្យព្រះរាជបុត្រាដ៏ជាព្រះរស់នៅក្នុងលក្ខណៈបែបជាមនុស្សពិតប្រាកដ ដោយទ្រង់មានលក្ខណៈជាសាច់ឈាមធម្មតា មានគំនិត មានឆន្ទៈ ផ្លូវចិត្ត និងសមត្ថភាពដើមនៃភាពជាមនុស្ស។ ក្នុងនាមជាព្រះរាជបុត្រាដែលបានយាងមកយកកំណើតជាមនុស្ស ព្រះយេស៊ូវបានដកបទពិសោធន៍រាល់ភាពល្អ និងកម្សោយនៃភាពជាមនុស្សទាំងស្រុង។ «ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង» (លូកា ២:៥២)។ ទ្រង់បានដកពិសោធន៍ក្នុងការយំសោក និងក្តីអំណរ

ទ្រង់ក៏បានរងទុក្ខហើយសុគត និងមានព្រះជន្មរស់ពីសុគតឡើងវិញ ដោយសិរីល្អដែរសម្រាប់ជាក្តីសង្គ្រោះរបស់រាស្ត្រទ្រង់ (យ៉ូហាន ១១:៣៣, ៣៥; ១៩:៣០; ១កូរិនថូស ១៥:៣-៤)។

## ៨. ប៉ុន្តែ ព្រះរាជបុត្រាមិនមែនជាប់ក្រោមព្រំដែននៃភាពជាមនុស្សទាំងស្រុងនោះទេ ព្រោះទ្រង់បន្តប្រព្រឹត្តិ និងគិតដោយប្រើភាពជាព្រះរបស់ទ្រង់

យើងមើលឃើញសេចក្តីពិតនេះយ៉ាងច្បាស់តាមរយៈព្រះរាជបុត្រា ដែលបានយាងមកយកកំណើតជាមនុស្ស ទ្រង់បន្តទ្រទ្រង់ចក្រវាលនេះ (កូឡុស ១:១៦-១៧; ហេព្រើរ ១:៣) រួមទាំងសកម្មភាពផ្សេងៗរបស់ទ្រង់នៅក្នុងជីវិត និងព័ន្ធកិច្ចរបស់ទ្រង់ដែរ។ ព្រះគ្រីស្ទមានលក្ខណៈពីរយ៉ាងផ្សេងពីគ្នា ហើយលក្ខណៈនីមួយៗសុទ្ធតែរក្សាភាពដោយឡែករបស់ខ្លួន ដោយមិនមានលក្ខណៈប្រឆាំងគ្នាឡើយ តែព្រះរាជបុត្រាអាចប្រើលក្ខណៈទាំងពីរនោះក្នុងពេលតែមួយបាន។ ដោយហេតុនេះហើយបានជាភាពជាមនុស្សមិនបានរារាំងព្រះរាជបុត្រាពីការដែលទ្រង់អាចប្រើភាពជាព្រះរបស់ទ្រង់ទេ។

ពេលវេលា និងរបៀបដែលព្រះរាជបុត្រាប្រើលក្ខណៈទាំងពីរនេះ ត្រូវបានពន្យល់យ៉ាងច្បាស់តាមរយៈទំនាក់ទំនងនៃព្រះត្រៃឯកដែលបានសម្រេចប្រវត្តិសាស្ត្រនៃសេចក្តីសង្គ្រោះរបស់យើង។ ព្រះរាជបុត្រាដែលតែងតែធ្វើអ្វីៗដោយមិនផ្តាច់រូបអង្គទ្រង់ផ្ទាល់ចេញពីព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធ បានបន្តធ្វើការនោះរហូត ប៉ុន្តែឥឡូវនេះទ្រង់បានធ្វើកិច្ចការក្នុងនាមជា

ព្រះរាជបុត្រាដែលស្ដាប់បង្គាប់ ដោយធ្វើជាអង្គតំណាង ក៏ដូចជាអង្គជំនួស ការតាំងសញ្ញារបស់យើងដែរ។ នៅក្នុងការយាងមកយកកំណើតជាមនុស្ស ព្រះរាជបុត្រាមិនបានបាត់បង់ភាពជាព្រះ ឬក៏ភាពជាមនុស្សរបស់ទ្រង់ឡើយ។

## ៩. តាមរយៈការដែលព្រះរាជបុត្រាបានមកយកកំណើតជាមនុស្ស ព្រះអង្គបានក្លាយជាមនុស្សដំបូងនៃការកើតជាថ្មី ហើយទ្រង់ក៏ជាអ្នកកណ្ដាល និងជាសិរសានៃការតាំងសញ្ញាថ្មីដ៏អស្ចារ្យដែរ

ក្នុងនាមជាព្រះរាជបុត្រាដែលបានយាងមកយកកំណើតជាមនុស្ស តាមរយៈជីវិត ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង ទ្រង់បានត្រឡប់ការដំបូងរបស់លោក អ័ដាម និងក្លាយទៅជាអ័ដាមចុងក្រោយ ហើយទ្រង់ក៏ជាអ្នកនាំមុខ និងជាអ្នកមានជ័យជម្នះដ៏អស្ចារ្យរបស់យើងដែរ (ហេព្រើរ ២:១០)។ ជាលទ្ធផលនៃការយាងមកយកកំណើតជាមនុស្ស គឺព្រះដ៏ជាព្រះរាជបុត្រាមានលក្ខណៈដ៏ល្អឥតខ្ចោះក្នុងការបំពេញរាល់តម្រូវការរបស់យើង ជាពិសេសតម្រូវការនៃការចេះអត់ទោស (ហេព្រើរ ២:៥-១៨; ៧:២២-២៨; ៩:១៥-១០:១៨)។

## ១០. ព្រះដ៏ជាព្រះរាជបុត្រាដែលបានយាងមកយកកំណើតជាមនុស្ស គឺជាព្រះដ៏អង្គឯក ហើយមានតែទ្រង់មួយអង្គគត់ដែលជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះ

ព្រះយេស៊ូវនៅក្រោមចំណាត់ថ្នាក់មួយដ៏ឯកអង្គ។ បើមិនមានការយាងមកយកកំណើត និងការសម្រេចរបស់ព្រះគ្រីស្ទសម្រាប់យើង នោះយើងប្រាកដជាមិនអាចទទួលបានសេចក្ដីសង្គ្រោះឡើយ ដ្បិតព្រះដ៏ពេញដោយសិរីល្អ និងសីលធម៌ដ៏ល្អឥតខ្ចោះមិនអាចលាយលំជាមួយមនុស្សមានបាបបានឡើយ (យ៉ូហាន ១៤:៦; កិច្ចការ ៤:១១)។

ក្នុងនាមជាព្រះរាជបុត្រាដ៏ជាព្រះ មានតែទ្រង់ប៉ុណ្ណោះដែលអាចបំពេញភាពស្កប់ស្កល់នៃការជំនុំជម្រះរបស់ព្រះជាម្ចាស់ចំពោះយើង និងការទាមទារឲ្យមានការស្ដាប់បង្គាប់ដ៏គ្រប់លក្ខណ៍បាន (រ៉ូម ៥:១២-២១)។

ក្នុងនាមជាព្រះរាជបុត្រាដែលបានយាងមកយកកំណើតជាមនុស្ស មានតែទ្រង់ប៉ុណ្ណោះដែលអាចយល់ពីអារម្មណ៍យើង ព្រោះទ្រង់ជាអ្នកតំណាង និងជាអ្នកជំនួសយើង (ហេព្រើរ ៥:១)។

មានតែព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះអម្ចាស់នៃយើងប៉ុណ្ណោះ ដែលអាចសម្រេចសេចក្ដីសង្ឃឹមនៃសេចក្ដីសង្គ្រោះរបស់យើងសម្រាប់ការបង់ថ្លៃលោះបាប និងការស្ដាររូបអង្គរបស់ព្រះជាម្ចាស់ឡើងវិញបាន (រ៉ូម ៣:២១-២៦; ហេព្រើរ ២:៥-១៨)។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Stephen J. Wellum
បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់, លោក អ៊ុន ជ័យរិទ្ធ, លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.thegospelcoalition.org/article/10-things-you-should-know-about-the-incarnation/ ដោយមានការអនុញ្ញាត។

# ៦

# ការចែកចាយទីបន្ទាល់នៅពេលល្ងាអេល

នៅក្នុងរដូវកាលនាពេលបុណ្យឈប់សម្រាក យើងមានឱកាសច្រើនណាស់ក្នុងការផ្សាយដំណឹងល្អ។ រវាងការជួបជុំគ្នាជាគ្រួសារ និងការមានដំណើរកំសាន្ត ជារឿយៗយើងឃើញថា យើងមានឱកាសចំណាយពេលជាមួយនឹងគ្រួសារ និងមិត្តភក្តិជាច្រើនៗដោយគ្មានការប្រញាប់ប្រញាល់ទៅនេះទៅនោះឡើយ។ តើយើងនឹងចំណាយពេលវេលាបែបនោះដោយរបៀបណាទៅ? តើយើងត្រៀមខ្លួនហើយឬនៅក្នុងការចែកចាយពីក្តីសង្ឃឹមដែលយើងមាន? ឬក៏ថា តើយើងនឹងទាញយកទូរស័ព្ទទំនើបៗរបស់យើងមកចុចលេងអូសចុះអូសឡើយ ខណៈពេលដែលយើងកំពុងជួបជុំគ្នា?

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទក៏អាចផ្សាំងបានដែរ សូម្បីតែមនុស្សដែលមានបាបដ៏សាហាវឃោរឃៅ ដូចសាច់រឿងនៅខាងលើ ហើយបន្ទាប់មកចាត់ឲ្យគាត់ត្រឡប់ទៅផ្ទះវិញ ដើម្បីផ្សព្វផ្សាយដំណឹងល្អជាមួយនឹងគ្រួសាររបស់គាត់ ដែលអាចឃើញនូវចំណុចផ្លាស់ប្រែដ៏ធំមហិមាក្នុងជីវិតរបស់គាត់។ ដំណឹងល្អមួយនេះ ដែលអាចបំផ្លាស់បំប្រែនៅសម័យនានាក៏អាចផ្លាស់ប្រែជីវិតយើងបានផងដែរ ហើយថែមទាំងផ្តល់នូវអំណរដល់យើងទៀតផង។ យើងក៏គួរប្រើឱកាសនារដូវបុណ្យណូអែលនេះ ដើម្បីនឹងចែកចាយដំណឹងល្អមួយនេះទៅកាន់អ្នកដទៃ។ ខាងក្រោមនេះគឺជាចំណុច១៥យ៉ាងដែលលោកគ្រូ ស៊ី. អេឆ. ស្ពើចិន (C.H. Spurgeon) បានលើកឡើង៖

១. ចូររាប់ការដែលលោកអ្នកទទួលបានការរំដោះថា ជាបេសកកម្មនៃដំណឹងល្អរបស់លោកអ្នកផងដែរ។

២. ចូរចាត់ទុករដូវកាលបុណ្យណូអែលថា ជាពេលវេលាដ៏ចម្បងមួយសម្រាប់ចែកចាយដំណឹងល្អ។

៣. ចូរព្យាយាមចែកចាយដំណើររឿងនៃព្រះគុណរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់លោកអ្នក។

៤. ចូរប្រើប្រាស់ទីបន្ទាល់របស់លោកអ្នកជាការស្តារអ្នកជឿផ្សេងៗឡើងវិញ។

៥. ចូររំពឹងទុកថា លោកអ្នកនឹងជួបប្រទះភាពតានតឹង។ ដូច្នេះ សូមអធិស្ឋានឲ្យអ្នកស្តាប់បើកចិត្តទទួលជឿ ពេលដែលលោកអ្នកចែកចាយទៅកាន់អស់អ្នកដែលមិនទាន់ជឿ។

៦. ចូរត្រៀមខ្លួនជាស្រេចក្នុងការឆក់យកឱកាស ដើម្បីចែកចាយទីបន្ទាល់របស់លោកអ្នកមួយទល់នឹងមួយ។

៧. ចូរកុំរំពឹងថា លោកអ្នកនឹងមានការងាយស្រួលក្នុងការចែកចាយ ជាពិសេសជាមួយអស់អ្នកដែលបានស្គាល់លោកអ្នកជាយូរណាស់មកហើយ។

៨. ចូរយកឈ្នះលើភាពភ័យខ្លាច ដើម្បីឲ្យលោកអ្នកអាចថ្វាយកិត្តិយសចំពោះក្តីស្រឡាញ់នៃព្រះសង្គ្រោះសម្រាប់លោកអ្នកបាន។

៩. ចូរចែកចាយទីបន្ទាល់របស់លោកអ្នកឲ្យមានពេញទៅដោយការអរព្រះគុណដល់ព្រះជាម្ចាស់។

១០. ចូរចែកចាយទីបន្ទាល់របស់លោកអ្នកដោយមានការបន្ទាបខ្លួន មិនមែនដោយរបៀបមើលងាយមើលថោកអ្នកផ្សេងនោះទេ។

១១. ចូរចែកចាយទីបន្ទាល់របស់លោកអ្នកដោយសេចក្តីពិត ហើយកុំថែមរបោយដោយនិយាយបំផ្លើសឡើយ។

១២. ចូរចែកចាយទីបន្ទាល់របស់លោកអ្នកយ៉ាងម៉ឺងម៉ាត់ មិនមែនជាការលេងសើចទេ។

១៣. ចូរកុំភ្លេចចំណាយពេលផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ក្នុងរដូវកាលបុណ្យណូអែលនេះ។

១៤. ចូរពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធក្នុងការចែកចាយ។

១៥. ចូរចងចាំថា៖ ទីបន្ទាល់របស់លោកអ្នកនៅក្នុងរដូវកាលបុណ្យណូអែល គឺជាការឆ្លុះបញ្ចាំងពីជីវប្រវត្តិរបស់លោកអ្នកនាគ្រា

អស់កល្បជានិច្ច។

## ម៉ាកុស ៥:១-២០៖

១នោះក៏មកដល់ស្រុកគេរ៉ាស៊ីននៅត្រើយសមុទ្រម្ខាង។ ២កាលទ្រង់បាន
យាងឡើងពីទូក ស្រាប់តែមានមនុស្សម្នាក់ដែលមានអារក្សអសោចិ៍ចូល វា
ចេញពីក្នុងផ្នូរខ្មោចមកជួបនឹងទ្រង់ ៣វានៅតែក្នុងផ្នូរខ្មោច ឥតមានអ្នកណា
អាចនឹងចងវាជាប់ទៀតបានទេ ទោះបើយកច្រវាក់ទៅដាក់ក៏ពុំបានផង។
៤ដ្បិតគេបានដាក់ខ្នោះដាក់ច្រវាក់វាជាច្រើនដងហើយ ប៉ុន្តែវាចេះតែកាច់
ច្រវាក់បំបាក់ខ្នោះចោលអស់ ហើយគ្មានអ្នកណាអាចនឹងកម្រាបវាបានដែរ។
៥វានៅក្នុងផ្នូរនៅលើភ្នំ ទាំងស្រែក ហើយយកថ្មមកអារសាច់ខ្លួន ទាំងយប់
ទាំងថ្ងៃជានិច្ច។ ៦កាលវាឃើញព្រះយេស៊ូវពីចម្ងាយក៏រត់ទៅក្រាបសំពះទ្រង់
៧ស្រែកដោយសម្រែកជាខ្លាំងថា «ឱព្រះយេស៊ូវ ជាព្រះរាជបុត្រាព្រះដ៏ខ្ពស់
បំផុតអើយ តើទ្រង់ហើយនឹងទូលបង្គំមានរឿងអ្វីនឹងគ្នា ទូលបង្គំសូមទ្រង់
ឲ្យស្បថដោយព្រះថា មិនធ្វើទុក្ខទូលបង្គំទេ?» ៨វាទូលដូច្នោះពីព្រោះទ្រង់
កំពុងតែមានបន្ទូលថា ម្នាល អារក្សអសោចិ៍ ចូរថយចេញពីមនុស្សនេះទៅ
៩រួចទ្រង់សួរវាថា ឯងឈ្មោះអី វាទូលឆ្លើយថា ទូលបង្គំឈ្មោះ «កងទ័ព» ពី
ព្រោះយើងខ្ញុំមានគ្នាច្រើន ១០នោះវាទទូចអង្វរសូមកុំឲ្យទ្រង់បណ្តេញវារាល់គ្នា
ចេញពីស្រុកនោះឡើយ។ ១១រីឯនៅទីនោះ មានហ្វូងជ្រូកយ៉ាងធំ កំពុងតែរក
ស៊ីនៅចង្កេះភ្នំ ១២ហើយអារក្សទាំងនោះទូលអង្វរទ្រង់ថា សូមឲ្យយើងរាល់គ្នា
ទៅជ្រក នៅក្នុងជ្រូកទាំងនោះចុះ។ ១៣នោះទ្រង់ក៏អនុញ្ញាតឲ្យភ្លាម រួចកាល
វិញ្ញាណអារក្សអសោចិ៍ទាំងនោះបានចេញហើយ វាក៏ចូលទៅក្នុងជ្រូក ហើយ

ហ្វូងជ្រូកប្រហែល២ពាន់រូប ក៏បោលម្នីម្នាតាមភ្នំចោត ធ្លាក់ទៅក្នុងសមុទ្រ
លង់ទឹកស្លាប់អស់ទៅ។ ១៤ឯពួកអ្នកគង្វាលជ្រូក គេរត់ទៅក្នុងទីក្រុង ហើយ
ក្នុងស្រុកស្រែសាសព្វប្រាប់ពីរឿងនោះ រួចមនុស្សទាំងអស់ចេញមកមើលការ
ដែលបានកើតឡើង។ ១៥គេមកឯព្រះយេស៊ូវ ហើយឃើញមនុស្សដែលពីដើម
មានអារក្សចូល កំពុងតែអង្គុយទាំងស្លៀកពាក់ មានស្មារតីដឹងខ្លួនឡើង គឺជា
អ្នកដែលមានអារក្សទាំងកងចូលនោះឯង រួចគេស្ញែងខ្លាច។ ១៦ពួកអ្នកដែល
បានឃើញការនោះ ក៏ពណ៌នាប្រាប់ដល់ជនគ្រប់គ្នាតាមការដែលកើតឡើង
ដល់អ្នកនោះជាយ៉ាងណា ហើយពីដំណើរហ្វូងជ្រូកផង។ ១៧នោះគេចាប់តាំង
ទូលអង្វរ សូមឲ្យទ្រង់យាងចេញពីស្រុកគេទៅ។ ១៨កាលទ្រង់បានយាងចុះ
ទូក នោះអ្នកដែលអារក្សចូលពីដើម គាត់ក៏សូមទៅជាមួយនឹងទ្រង់ ១៩តែទ្រង់
មិនអនុញ្ញាតទេ ដោយបន្ទូលថា ចូរទៅផ្ទះទៅ ហើយប្រាប់បងប្អូនឯងពីការធំ
ទាំងម៉្លេះ ដែលព្រះអម្ចាស់បានមេត្តាប្រោសដល់ឯងវិញ។ ២០គាត់ក៏ចេញទៅ
ចាប់តាំងប្រកាសប្រាប់ នៅស្រុកដេកាប៉ូល ពីការធំទាំងម៉្លេះ ដែលព្រះយេស៊ូវ
បានប្រោសដល់ខ្លួន នោះមនុស្សទាំងអស់ក៏អស្ចារ្យក្នុងចិត្ត។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Tony Reinke
បកប្រែដោយ៖ លោក ឈាង បូរ៉ា និងលោក ទេព រ៉ូ
កែសម្រួលដោយ៖ លោកស្រី ឡូញ ណារ៉ុង, លោក ម៉េង មនោ, លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/articles/how-to-share-your-story-this-christmas ដោយមានការអនុញ្ញាត។

# ៧៥ចំណុច សម្រាប់បង្រៀនកូនៗពេលបុណ្យណូអែល

រដូវណូអែលជារដូវដ៏ល្អមួយក្នុងការផ្តល់ជាឱកាសឲ្យយើងបង្រៀនសេចក្តីពិតអំពីដំណឹងល្អទៅក្នុងចិត្តរបស់កូនៗយើង។ នេះគឺជាពេលវេលាដ៏ល្អក្នុងការប្រាប់កូនៗថា ព្រះយេស៊ូវគឺជាកាដូដ៏ល្អបំផុតដែលពួកគេអាចទទួលបានក្នុងជីវិតនេះ។

ខាងក្រោមនេះគឺជាចំណុចស្តីពីសេចក្តីពិតដ៏សំខាន់ៗទុកបង្រៀនកូនៗនៅថ្ងៃបុណ្យណូអែលៈ

## ១. រឿងនៃសេចក្តីប្រោសលោះ

បួនអាទិត្យមុនថ្ងៃទី២៥នៃខែ១២ យើងអាចយកឱកាសនោះ ដើម្បីបង្រៀន

កូនៗរបស់យើងពីរឿងកំណើតរបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរឲ្យពួកគេបានស្គាល់។

នៅក្នុងគ្រួសាររបស់យើងខ្ញុំ រៀងរាល់ថ្ងៃក្នុងអំឡុងបួនអាទិត្យមុនថ្ងៃទី២៥ នៃខែ១២ យើងចូលចិត្តរៀនពីសាច់រឿងនៃការប្រោសលោះ ដោយចាប់ផ្តើមពីការដែលព្រះជាម្ចាស់បង្កើត ហើយរៀនរហូតដល់ថ្ងៃកំណើតរបស់ព្រះគ្រីស្ទនៅថ្ងៃបុណ្យណូអែល។ ពួកយើងនាំគ្នាពិភាក្សាពីការធ្លាក់ចុះក្នុងអំពើបាប និងពីសេចក្តីសន្យារបស់ព្រះជាម្ចាស់ស្តីពីព្រះសង្គ្រោះដែលមានចែងក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥។ ពួកយើងបាននាំគ្នាអានអំពីសេចក្តីសន្យារបស់ទ្រង់ចំពោះលោក អ័ប្រាហាំ និងការអះអាងរបស់ទ្រង់ម្តងហើយម្តងទៀតនៅក្នុងគម្ពីរសញ្ញាចាស់។ យើងនិយាយពីរឿងលោក ម៉ូសេ និងបុគ្គលម្នាក់ទៀតដែលគាត់ល្អប្រសើរជាងលោក ម៉ូសេដែលនឹងត្រូវយាងមក (ហេព្រើរ ៣:៣-៦)។ យើងបាននាំគ្នាអានពីសេចក្តីទំនាយនៅក្នុងកណ្ឌគម្ពីរ អេសាយ ៧:១៤; ៩:១-២, ៦-៧; ១១:១; ៣៥:៥-៦; ៤០:៣-៥; ៤២:១-៦; ៥២:១៣-៥៣:១២; ៦១:១-២។ល។ យើងបាននាំគ្នាមើលពីរបៀបដែលព្រះគម្ពីរបានចង្អុលបង្ហាញទៅព្រះអង្គសង្គ្រោះរបស់យើង។

## ២. ការបន្ទាបខ្លួនរបស់ព្រះគ្រីស្ទ

សម្រាប់អស់អ្នកដែលមិនជឿ នៅពេលរដូវកាលនៃថ្ងៃសម្រាកមកដល់ពួកគេច្រើនចាយវាយលើសពីចំណូលរបស់ខ្លួន ហើយបង្ហាញពីភាពស្មុកស្មាញរបស់ខ្លួន ទាំងព្យាយាមធ្វើនូវគ្រប់ទាំងចំណុចដែលមើលទៅគឺថា

ល្អឥតខ្ចោះតែម្តង។ ប៉ុន្តែទោះជាយ៉ាងណាក្តី រឿងស្តីពីព្រះយេស៊ូវ គឺជារឿងនៃការបន្ទាបខ្លួន។ ថ្ងៃបុណ្យណូអែល គឺជាពេលវេលាដែលផ្តល់នូវឱកាសយ៉ាងល្អក្នុងការបង្រៀនកូនៗរបស់យើងពីខ្លឹមសារនៃអ្នកដែលធំជាងគេនៅក្នុងនគរស្ថានសួគ៌ (ម៉ាថាយ ២០:២៦-២៨)។ ចំណុចទាំងអស់នេះ គឺជាការបង្ហាញឲ្យយើងឃើញពីការបន្ទាបខ្លួនរបស់ទ្រង់ដូចជា៖ មាតាបិតារបស់ទ្រង់ កន្លែងកំណើតរបស់ទ្រង់ និងស្រុកកំណើតរបស់ទ្រង់ និងគ្រប់ទាំងសកម្មភាពដែលទ្រង់បានយាងមកយកនិស្ស័យជាសាច់ឈាម ទាំងអស់នេះគឺជាភស្តុតាងដែលបង្ហាញឲ្យយើងឃើញថា ទ្រង់បន្ទាបខ្លួន។

មនុស្សភាគច្រើន ពួកគេរំពឹងថា ព្រះមែស្ស៊ីនឹងយាងមកយកកំណើតនៅក្នុងវិមានដ៏ស្កឹមស្កៃ មិនមែននៅក្នុងក្រោលសត្វនោះឡើយ។ មនុស្សភាគច្រើនរំពឹងថា ទ្រង់រស់នៅក្នុងវង្សត្រកូលស្តេច មិនមែនមករស់នៅល្វេមល្វាមនោះទេ។ មនុស្សភាគច្រើនរំពឹងថា ទ្រង់នឹងមកយកជ័យជម្នះលើចក្រភពរ៉ូម មិនមែនមកឲ្យពួកគេចាប់ឆ្កាងនោះទេ។ សូមអានកណ្ឌគម្ពីរ ភីលីព ២:១-១១ បន្ទាប់មកបង្ហាញដល់កូនៗរបស់លោកអ្នកអំពីការបន្ទាបខ្លួនរបស់ព្រះគ្រីស្ទតាមរយៈខគម្ពីរនោះ។

## ៣. ព្រះជាម្ចាស់ធ្វើការតាមរយៈភាពកម្សោយ

បរិបទស្រដៀងគ្នាមួយទៀតដែលយើងអាចបង្រៀនកូនៗនៅរដូវបុណ្យណូអែលនេះគឺ របៀបដែលព្រះជាម្ចាស់ធ្វើការតាមរយៈភាពកម្សោយ។ ព្រះជាម្ចាស់ច្រើនតែជ្រើសរើសមនុស្សដែលមិនស័ក្តិសមនឹងឲ្យទ្រង់ប្រើ

ក៏ដូចជាមនុស្សកម្សោយ ព្រះអង្គបានប្រើប្រាស់ពួកគេនៅក្នុងរឿងនៃការប្រោសលោះរបស់ទ្រង់។ នាង ម៉ារា គឺជានារីសាមញ្ញធម្មតាម្នាក់ ជាស្ត្រីក្រីក្រចេញមកពីស្រុកដែលគ្មានអ្វីដែលគួរឲ្យសំខាន់នោះទេ។ ចំណែក សាវ័កពេត្រុស គាត់ក៏ជាម្នាក់ដែលមិនបានរៀនសូត្រអ្វីខ្ពង់ខ្ពស់នោះទេ គាត់គ្រាន់តែជាអ្នកនេសាទម្នាក់ប៉ុណ្ណោះ។ យើងអាចនឹងឃើញសិរីល្អរបស់ព្រះជាម្ចាស់តាមរយៈការដែលទ្រង់ធ្វើការតាមរយៈភាពកម្សោយរបស់យើង។ យើងអាចមើលឃើញពីការនេះបានយ៉ាងច្បាស់ គឺនៅក្នុងការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងជំនួសបាបរបស់យើង និងការដែលទ្រង់បានមានព្រះជន្មរស់ឡើងវិញ បន្ទាប់ពីបីថ្ងៃក្រោយដែលទ្រង់សុគត ជាពេលវេលាដែលអះអាងពីជ័យជម្នះរបស់យើងទៅលើអំពើបាប និងសេចក្តីស្លាប់។

## ៤. ព្រះជាម្ចាស់រក្សាពាក្យសន្យារបស់ទ្រង់

មានសេចក្តីពិតដ៏សំខាន់មួយទៀតនៅរដូវកាលនេះដែលយើងគួរផ្តោតលើពេលបង្រៀនកូនៗរបស់យើងនោះគឺថា ព្រះជាម្ចាស់រក្សាពាក្យសន្យារបស់ទ្រង់។ យើងអាចចាប់ផ្តើមជាមួយនឹងសេចក្តីសន្យារបស់ព្រះសង្គ្រោះបន្ទាប់ពីការធ្លាក់ក្នុងអំពើបាប មើលក្នុងគម្ពីរសញ្ញាចាស់ មើលត្រង់សេចក្តីសន្យានៃការប្រោសលោះរាស្ត្ររបស់ទ្រង់ ហើយសេចក្តីសន្យានោះត្រូវបានបំពេញទាំងស្រុងដោយព្រះគ្រីស្ទ។

## ៥. ព្រះនាមរបស់ព្រះគ្រីស្ទ

កាលពីឆ្នាំទៅ កូនៗរបស់ខ្ញុំបានរៀនពីឈ្មោះផ្សេងៗរបស់ព្រះយេស៊ូវនៅរដូវកាលបុណ្យណូអែលអស់បួនអាទិត្យមុនថ្ងៃទី២៥នៃខែ១២។ ពួកយើងបានរៀនពីព្រះនាមរបស់ទ្រង់ដូចជា ព្រះមែស៊ី កូនចៀមនៃព្រះ អេម៉ាញូអែល អាល់ហ្វា និងអូមេហ្គា និងព្រះអម្ចាស់នៃសេចក្តីសុខសាន្តជាដើម។ល។ ខ្ញុំបានបង្រៀនកូនៗពីព្រះនាមរបស់ព្រះយេស៊ូវ ក៏ដូចជាអត្ថន័យដល់ពួកគេ ដើម្បីជួយពួកគេកាន់តែស្គាល់ព្រះយេស៊ូវថែមទៀត ក៏ដូចជាឲ្យពួកគេកាន់តែស្គាល់ពីលក្ខណសម្បត្តិ និងកិច្ចការដែលទ្រង់បានបំពេញសម្រេច។ យើងបានសរសេរព្រះនាមទាំងអស់នោះ រួចមកយកឈ្មោះទាំងនោះមកតភ្ជាប់គ្នាដូចជាច្រវាក់ បន្ទាប់ពីបានរៀនរៀងរាល់ថ្ងៃ។ របៀបមួយទៀតដែលយើងអាចរៀនពីព្រះនាមទាំងនោះគឺ យើងអាចសរសេរព្រះនាមរបស់ទ្រង់ទាំងអស់លើកូនក្រដាសស្អាតៗ ផាត់ពណ៌ឲ្យស្អាត ហើយយកទៅតាំងនៅលើដើមណូអែល ទុកសម្រាប់រាល់ពេលដែលយើងសិក្សាពីព្រះនាមទ្រង់។

សូមឆក់យកអត្ថប្រយោជន៍ចេញពីឆ្នាំនេះ ដើម្បីបង្រៀនកូនៗពីកំណើតព្រះគ្រីស្ទ ដោយចំណាយពេលអានព្រះបន្ទូលជាមួយពួកគេ ហើយបង្ហាញពួកគេពីព្រះមែស៊ីដែលបានយាងមកដូចតាមសេចក្តីសន្យា និងពីរបៀបដែលទ្រង់បានបំពេញសេចក្តីសន្យាតាមរយៈព្រះឱរសដែលមកយកកំណើតនៅភូមិបេថ្លេហិម។ សូមជួយកូនៗឲ្យមើលឃើញថា ព្រះយេស៊ូវគឺជាកាដូដ៏ល្អបំផុតដែលពួកគេអាចទទួលបាន និងជាកាដូដ៏ល្អបំផុតដែលពួកគេអាចជូនដល់អ្នកផ្សេងៗទៀតបានផងដែរ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Christina Fox
ដកស្រង់ និងបកប្រែដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់, លោក ណាថាន វ៉ែល និងលោក ទេព រ៉ូ
កែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/articles/five-things-to-teach-your-children-this-christmas ដោយមានការអនុញ្ញាត។

# ៨ អ្នកកាន់ទុក្ខម្នាក់

ខណៈពេលដែលចុងឆ្នាំខិតជិតមកដល់ សឹងតែគ្រប់កន្លែងដែលយើងទៅសុទ្ធតែមានអ្នកប្រាប់យើងថា «រីករាយថ្ងៃបុណ្យអរព្រះគុណ!» «រីករាយថ្ងៃបុណ្យណូអែល!» «រីករាយឆ្នាំថ្មី!» មើលទៅ យើងគួរតែមានភាពរីករាយអរសប្បាយរហូត។

ប៉ុន្តែ ចំពោះអស់អ្នកដែលទើបតែបាត់បង់មនុស្សដែលពួកគាត់ស្រឡាញ់ ថ្ងៃបុណ្យទាំងនេះហាក់បីដូចជាពេលមួយដែលពួកគាត់ត្រូវតែឆ្លងកាត់មួយគ្រាសិន ជាជាងមានភាពអរសប្បាយ។ ប្រពៃណីវប្បធម៌ និងព្រឹត្តិការណ៍ដែលអាចបន្ថែមក្ដីអំណរ និងអត្ថន័យដ៏មហិមាទៅលើរដូវកាលបែបៗនោះ គឺតាមពិតទៅមានពេញទៅដោយការរម្លឹកដ៏ឈឺចាប់អំពីបុគ្គលដែលយើងស្រឡាញ់ ដែលឥឡូវនេះគាត់មិនមានវត្តមានក្នុងការចូលរួមកម្មវិធីទាំងនេះ

ទៀតទេ។ មានមនុស្សជាច្រើនប្រាថ្នាចង់រកកន្លែងដ៏ស្ងៀមស្ងាត់មួយ ដើម្បីពួនរហូតដល់ថ្ងៃទី២ខែមករាសិន។

ទោះបើយើងមិនអាចព្យាបាលភាពខ្លោចផ្សានៃការឈឺចាប់របស់អស់អ្នកដែលយើងកំពុងនៅជិត ដែលពួកគាត់កំពុងកាន់ទុក្ខដោយសារបាត់បង់ ក៏យើងនៅអាចជួយរំលែកទុក្ខព្រួយនៃការឈឺចាប់របស់ពួកគាត់ដោយព្យាយាមយល់ពីអារម្មណ៍ថា តើការឈឺចាប់នោះវាមានអារម្មណ៍យ៉ាងណានៅក្នុងរដូវកាលបុណ្យបែបៗនេះ? អ្នកកាន់ទុក្ខប្រាថ្នាចង់ឲ្យដឹងយ៉ាងហោចណាស់សេចក្ដីពិត៥យ៉ាងក្នុងចំណោមសេចក្ដីពិតនានា ទាក់ទងនឹងរដូវកាលបុណ្យណូអែល។

## ១. សូម្បីតែពេលវេលាដ៏ល្អបំផុតក៏នៅមានការកត់សម្គាល់ថា មាននរណាម្នាក់អវត្តមានដែរ

ខ្ញុំនឹកចាំពីការសន្ទនាមួយ ដែលខ្ញុំបានជួបជាមួយមិត្តភក្តិម្នាក់ ខណៈពេលដែលយើងត្រៀមខ្លួនចេញដំណើរកំសាន្តនៅថ្ងៃឈប់សម្រាកដ៏ខ្លីមួយ បន្ទាប់ពីកូនស្រីរបស់យើងទើបតែស្លាប់។ “ឯងទំនងជានឹងសប្បាយហើយ” គាត់និយាយមកខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែឯកភាពយ៉ាងពេញទីជាមួយនឹងគាត់ ប៉ុន្តែអ្វីដែលខ្ញុំមិនទាន់ដឹងនោះគឺអំពីរបៀបពន្យល់ថា នៅពេលដែលលោកអ្នកបាត់បង់សមាជិកណាម្នាក់នៅក្នុងក្រុមគ្រួសារ នោះសូម្បីតែពេលវេលាដ៏ល្អបំផុតក៏នៅមានការឈឺចាប់យ៉ាងខ្លាំងដែរ ព្រោះលែងមានសមាជិកមួយនោះទៀតហើយ។ ដូចជាមាននរណាបាត់ខ្លួន សូម្បីតែក្នុងថ្ងៃដ៏ល្អបំផុត

និងពិធីដ៏ឱឡារិកបំផុតក៏យើងនៅមានអារម្មណ៍សោកសៅមិនស្រទ្បះមុខ។

## ២. ការជួបជុំគ្នានៅមានចិត្តខ្លោចផ្សា

ខ្ញុំមិនដែលយល់ថា ហេតុអ្វីបានជាពេលដែលមានមនុស្សជាច្រើននៅជុំវិញអស់អ្នកដែលកំពុងកើតទុក្ខគឺជាពេលវេលាដ៏ពិបាកមួយសម្រាប់ពួកគាត់សោះ។ ការនិយាយលេងតិចតួចអាចជារឿងមួយដែលពួកគាត់ពិបាកនឹងធ្វើ ពេលដែលរឿងដ៏ធំមួយទើបតែបានកើតឡើង។ ការជួបអ្នកថ្មីនឹងបណ្តាលឲ្យការសន្ទនាគ្នាមានការសួរដេញដោលអំពីគ្រួសារ។ ការដើរចូលក្នុងបន្ទប់មួយដែលមានពេញទៅដោយអ្នកដែលមានដៃគូរ ខណៈពេលដែលដៃគូរជីវិតរបស់លោកអ្នកទើបតែស្លាប់ ឬក៏ការទៅចូលរួមកម្មវិធីដែលមានកូនក្មេងជាច្រើន ខណៈពេលដែលកូនរបស់លោកអ្នកទើបតែស្លាប់ក៏ការនោះគឺជាការរម្លឹកដ៏អួលដើមកអំពីអ្វីដែលលោកអ្នកបានបាត់បង់ដែរ។

ប្រសិនបើលោកអ្នកបានអញ្ជើញនរណាម្នាក់ ដែលកំពុងតែកាន់ទុក្ខ ឲ្យមកចូលរួមក្នុងកម្មវិធីរបស់លោកអ្នក សូមប្រាប់ពួកគាត់ឲ្យដឹងច្បាស់ថាលោកអ្នកយល់អំពីអារម្មណ៍ពួកគាត់ ប្រសិនបើពួកគាត់សុំដកខ្លួនចេញដោយមិនទៅចូលរួមទោះបើកម្មវិធីកៀកនឹងចាប់ផ្តើមភ្លាមៗហើយ ឬក៏ថាពួកគាត់អាចទៅចូលរួមបានតែមួយភ្លែតក៏ដោយ។

ប្រសិនបើលោកអ្នកទៅចូលរួមកម្មវិធីណាមួយ សូមទាក់ទងទៅកាន់អ្នកដែលកំពុងកាន់ទុក្ខ ហើយសួរពួកគាត់ថា តើខ្ញុំអាចទៅយកអ្នកដល់ផ្ទះបានដែរឬទេ ហើយកំដរអ្នកខណៈពេលដែលកំពុងចូលរួមកម្មវិធី ព្រោះលោកអ្នក

ចង់រំលែកទុក្ខគាត់។ ឬក៏ថា ពេលដែលលោកអ្នកជួបនរណាម្នាក់ដែលកំពុងកាន់ទុក្ខនៅកន្លែងកម្មវិធីសម្រាប់ពិធីជប់លៀង សូមប្រាប់ឲ្យគាត់ដឹងថា លោកអ្នកក៏កំពុងគិតអំពីបុគ្គលដែលគាត់ស្រឡាញ់ដែលបានស្លាប់ទៅដែរ ហើយសូមលើកទឹកចិត្តគាត់ឲ្យនិយាយអំពីអនុស្សាវរីយ៍ដែលគាត់បានសាងជាមួយនឹងបុគ្គលម្នាក់នោះ។ សូមកុំមានការភ័យខ្លាចក្នុងការនិយាយឈ្មោះនៃបុគ្គលដែលបានស្លាប់ទៅនោះឡើយ។ វានឹងផ្ដល់ភាពស្រាកស្រាន្តទៅកាន់អ្នកដែលមានអារម្មណ៍កើតទុក្ខ។

## ៣. សាច់ញាតិអាចបង្កឲ្យមានភាពពិបាក និងភាពប្រក្រតី

ការកាន់ទុក្ខគឺជាការពិបាកណាស់—សូម្បីតែ ហើយពិសេសជាមួយនឹងអស់អ្នកដែលស្គាល់យើងយ៉ាងជិតដិត។

ស្វាមីខ្ញុំហើយនិងខ្ញុំមើលខុសត្រូវកម្មវិធីនាចុងសប្ដាហ៍សម្រាប់ដៃគូរជីវិតដែលកូនៗខ្លួនបានស្លាប់ ហើយខ្ញុំបានកត់សម្គាល់ឃើញថា ប្រធានបទមួយដែលពួកគាត់តែងតែលើកឡើងនិយាយគឺទាក់ទងទៅនឹងភាពលំបាកនៃការចំណាយពេលជាមួយនឹងគ្រួសារសាច់ញាតិនាពេលបុណ្យនានា។ ពួកគាត់ដឹងថា មានសមាជិកគ្រួសារមួយចំនួនគិតថា ពួកគាត់បានកាន់ទុក្ខយូរល្មមគ្រប់គ្រាន់ហើយ ហើយចង់ឲ្យពួកគាត់បំភ្លេចចោល ហើយឆ្ពោះទៅមុខទៅ។ រីឯអ្នកផ្សេងទៀត ពួកគាត់ចង់ចាប់ផ្ដើមនិយាយអំពីបុគ្គលដែលបានស្លាប់បាត់ទៅ ប៉ុន្តែពួកគាត់មិនដឹងថា ត្រូវធ្វើបែបម៉េច។ ជាទូទៅ អ្វីមួយដែលបានកើតឡើងជារឿយៗគឺថា ឈ្មោះបុគ្គលដែលបានស្លាប់បាត់ទៅ

មិនដែលបានលើកឡើង ហើយការនោះបង្កឲ្យបុគ្គលដែលកំពុងតែកាន់ទុក្ខមានអារម្មណ៍ថា ពួកគាត់បានបំភ្លេចបុគ្គលដែលបានស្លាប់នោះចោលពីគ្រួសារបាត់ហើយ។ តើលោកអ្នកស្គាល់បុគ្គលណាម្នាក់ដែលកំពុងកើតទុក្ខដែលគាត់កំពុងធ្វើដំណើរចេញទៅជួបជុំគ្រួសារសម្រាប់រដូវកាលបុណ្យនេះដែរឬទេ? បើស្គាល់ លោកអ្នកអាចសួរអំពីសេចក្តីរំពឹងរបស់គាត់ដែលគាត់មានលើគ្រួសារគាត់ពេលទៅជួបជុំគ្នា។ ហើយប្រសិនបើពួកគាត់មានចិត្តចង់ឲ្យគ្រួសារគាត់នឹកចាំអំពីរឿងមួយចំនួន ទាក់ទងនឹងបុគ្គលដែលគាត់ស្រឡាញ់ ហើយបើពួកគាត់មានការភ័យខ្លាចថា ការនោះទំនងនឹងមិនកើតឡើង នោះលោកអ្នកអាចលើកទឹកចិត្ត ហើយជួយជូនដំណឹងទៅកាន់គ្រួសារគាត់មុនរដូវកាលនេះមកដល់ ដោយលើកឡើងយ៉ាងចំៗថា តើអ្វីទៅនឹងជួយឲ្យគាត់មានអារម្មណ៍ធូរស្បើយ ជាជាងរំពឹងថា គ្រួសារគាត់នឹងដឹងដោយឯងៗ។

## ៤. ការស្រក់ទឹកភ្នែកមិនមែនជាបញ្ហា

ចំពោះយើងជាច្រើននាក់ ការស្រក់ទឹកភ្នែកគឺជារឿងធម្មតាទេ ពេលដែលយើងកើតទុក្ខ ជាពិសេសទឹកភ្នែកដែលស្រក់ក្នុងពេលដែលគិតថា វាមិនគួរស្រក់។ ពេលខ្លះ អ្នកដែលកើតទុក្ខមានអារម្មណ៍ថា នៅពេលដែលអស់អ្នកដែលនៅជុំវិញខ្លួនពួកគាត់ឃើញទឹកភ្នែករបស់ពួកគាត់ នោះគឺពួកគាត់ត្រូវតែដោះស្រាយបញ្ហាដោយគិតថា សម្រែកទឹកភ្នែកទាំងនោះមានន័យថាពួកគាត់កំពុងតែមានបញ្ហាក្នុងការកើតទុក្ខ។ ប៉ុន្តែ វាជារឿងធម្មតាទេ ដែលការកាន់ទុក្ខបុគ្គលដែលយើងស្រឡាញ់ដែលបានបាត់បង់នឹងបង្ហាញខ្លួន

តាមរយៈទឹកភ្នែក។ ការស្រក់ទឹកភ្នែកមិនមែនជាខ្មាំងសត្រូវនោះទេ។ ទឹកភ្នែកមិនមែនជាការឆ្លុះបញ្ចាំងថាគ្មានជំនឿឡើយ។ ទឹកភ្នែកគឺជាអំណោយទានពីព្រះជាម្ចាស់ ដែលជួយលាងសម្អាតចោលនូវភាពឈឺចាប់ដ៏ខ្លាំងក្លានៃការបាត់បង់។

វាគឺជាអំណោយទានដ៏ល្អណាស់ក្នុងការដែលលោកអ្នកប្រាប់បុគ្គលដែលកាន់ទុក្ខថា ពួកគាត់មិនចាំបាច់ខ្មាសអៀនអ្វីទេក្នុងការយំនៅពេលដែលពួកគាត់នៅជាមួយនឹងលោកអ្នក ពោលគឺពួកគាត់អាចយំជាមួយនឹងលោកអ្នក។ ហើយអំណោយទានក៏កាន់តែល្អលើសនោះទៅទៀតគឺត្រង់ថា លោកអ្នកក៏យំជាមួយពួកគាត់សម្រាប់បុគ្គលដែលពួកគាត់ស្រឡាញ់ដែលត្រូវបានបាត់បង់ដែរ។ ទឹកភ្នែករបស់លោកអ្នកឆ្លុះបង្ហាញពីតម្លៃពីបុគ្គលដែលបានស្លាប់ ហើយក៏ជាការធានាអះអាងទៅកាន់ពួកគាត់ថា ពួកគាត់មិនមែននៅតែឯងក្នុងការនឹកបុគ្គលម្នាក់នោះទេ។

## ៥. វាអាចជាការពិបាកក្នុងការចងចាំថា ហេតុអ្វីរដូវបុណ្យណូអែលគឺជារដូវសប្បាយរីករាយ

អស់អ្នកដែលកើតទុក្ខដែលនៅក្បែរលោកអ្នកយល់អំពីអារម្មណ៍នៃការនឿយហត់ក្នុងជីវិត និងអំពីសេចក្តីស្លាប់នៅលើផែនដីនេះ ហេតុដូច្នេះហើយបានជាពួកគាត់ងឿងឆ្ងល់ថា តើឲ្យអស់អ្នកដែលនៅជុំវិញពួកគាត់មានអំណរបានដោយរបៀបណាទៅ។ ពួកគាត់ត្រូវឲ្យព្រះគ្រីស្ទបន្ធូរភាពឯកា និងការអស់សង្ឃឹមយ៉ាងខ្លាំងណាស់របស់គាត់នោះ។ ខណៈពេលដែលយើងមិន

ចង់អធិប្បាយដល់ពួកគាត់ យើងក៏ចង់ព្យាយាមរកឱកាស ដើម្បីចែកចាយជាមួយនឹងពួកគាត់អំពីភាពស្រណុកសុខស្រួល នឹងអំណរអរដែលអាចរកឃើញបានក្នុងការដែលព្រះផ្ទាល់បានយាងមកក្នុងព្រះគ្រីស្ទ ដើម្បីរំដោះយើង។

ជីវិតរបស់ព្រះគ្រីស្ទដែលបានចាប់ផ្ដើមនៅក្នុងស្នូកឈើក៏បានឈានដល់ទីបញ្ចប់នៃសេចក្ដីស្លាប់នៅលើឈើឆ្កាងផងដែរ។ ប៉ុន្តែ វាមិនមែនជាការស្លាប់ដែលគ្មានអត្ថន័យ គ្មានខ្លឹមសារ និងការគិតគូរនោះទេ។ វាគឺជាការស្លាប់ដែលយកឈ្នះលើសេចក្ដីស្លាប់ដោយមានព្រះជន្មរស់ឡើងវិញជាថ្មីម្ដងទៀត។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានពន្យល់ថា «ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្ដីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត» (ហេព្រើរ ២:១៤)។ អំណាចនៃសេចក្ដីស្លាប់ដែលឥឡូវនេះនាំឲ្យមានទុក្ខព្រួយជាច្រើននឹងមិននៅដូចនេះទៀតយ៉ាងអស់កល្បជានិច្ចឡើយ។ ចលនាដែលព្រះគ្រីស្ទបានបង្កើតឡើង ពេលដែលទ្រង់បានយកឈ្នះលើសេចក្ដីស្លាប់ក្នុងការយាងមកលើកទីមួយរបស់ទ្រង់នឹងបង្កើតជាផលផ្លែយ៉ាងពេញទីពេលដែលទ្រង់យាងត្រឡប់មកវិញ។

នេះគឺជាក្ដីសង្ឃឹមដ៏ធំបំផុតរបស់យើងនារដូវបុណ្យណូអែល ហើយនេះក៏ជាក្ដីសង្ឃឹមដែលយើងមានក្នុងការចែកចាយជាមួយនឹងអស់អ្នកដែលកំពុងកាន់ទុក្ខក្នុងរដូវបុណ្យណូអែលនេះដែរ។ ព្រះគ្រីស្ទដែលបានយាងមកយកកំណើតជាព្រះឱរស ហើយបានសុគតជំនួសយើងនឹងយាងមកវិញនៅថ្ងៃ

ខាងមុខ ដើម្បីនឹងសម្រេចនគរទ្រង់។ ហើយនៅពេលដែលទ្រង់ធ្វើបែបនោះ «ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ នឹងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ» (វិវរណៈ ២១:៤)។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Nancy Guthrie
បកប្រែដោយ៖ លោក ឈាង បូរ៉ា និងលោក ទេព រ៉ូ
កែសម្រួលដោយ៖ លោកស្រី ឡូញ ណារ៉ុង, លោក ម៉េង មនោ, លោក ឈាង បូរ៉ា,លោក ទេព រ៉ូ, លោក ខែម បូឡុង,លោក ប៊ុន ធីម៉ូថេ,លោក ឯក សត្យានិង លោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/articles/what-grieving-people-wish-you-knew-at-christmas ដោយមានការអនុញ្ញាត។

# ៩ ការអស្ចារ្យនៃការដែលព្រះបន្ទូលបានយាងមក

បុណ្យណូអែល៖ ការអស្ចារ្យអំពីការដែលព្រះបន្ទូលដ៏គង់នៅគ្រប់ទីកន្លែងបានយាងមកយកកំណើតជាមនុស្ស

«ដ្បិតព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ» (ហេព្រើរ ១៣:៨)

រៀងរាល់ឆ្នាំ នៅពេលនេះគឺជាពេលដែលយើងអបអរសាទរអំពីកំណើតរបស់ព្រះឱរសព្រះយេស៊ូវ និងអំពីស្ត្រីព្រហ្មចារី ម៉ារា។ល។ ខ្ញុំគិតថា មិនមានមនុស្សគ្រប់គ្នាដែលកំពុងអបអរសាទរបុណ្យណូអែល ដឹងថាខ្លួនកំពុងអបអរសាទរការដែលទ្រង់យាងមកយកកំណើតជាមនុស្សទេ។ ការអស្ចារ្យផ្សេងៗទៀតដែលបានកើតឡើង គឺដោយសារតែការអស្ចារ្យដ៏សំខាន់នេះ៖ ព្រះបានយកកំណើតជាមនុស្ស។ ក្នុងការដែលទ្រង់យាងមកយកកំណើតជាអ្នកស្រុកណា

សារ៉ែតឈ្មោះយេស៊ូវ តាមរយៈការយាងមកសណ្ឋិតរបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រះបន្ទូលមិនបានឈប់ធ្វើជាព្រះនោះឡើយ។ ព្រះឱរសយេស៊ូវមានភាពជាព្រះ១០០% និងមនុស្ស១០០% តាំងពីពេលដែលទ្រង់បានយាងមកទំនៅក្នុងផ្ទៃពោះរហូតដល់ពេលទ្រង់ប្រសូតមកក្នុងស្នូកសត្វ។ នោះហើយជាអត្ថន័យនៃបុណ្យណូអែល។យើងនឹងមានអារម្មណ៍ស្ញុគ្រស្មាញយ៉ាងខ្លាំង នៅពេលដែលយើងចំណាយពេលវេលាយូរក្នុងការគិតអំពីការដែលព្រះយេស៊ូវជាព្រះ១០០% និងជាមនុស្ស១០០% ក្នុងពេលតែមួយ។ ទោះបើគោលជំនឿនៃការយាងមកយកកំណើតពិតជាមានការបង្ខិតបង្ខំចំពោះយើង មានចំណុចដ៏អស្ចារ្យ មានភាពស៊ីគ្នានឹងព្រះបន្ទូល និងចំណុចចាំបាច់សម្រាប់ការសង្គ្រោះក៏ដោយ ក៏នៅមានចំណុចដែលពិបាកយល់ផងដែរ។ ប៉ុន្តែ មិនថ្វីទេ។ បើនិយាយឲ្យចំទៅ ការដែលព្រះយេស៊ូវយាងមកយកកំណើតជាមនុស្សមិនមែនដើម្បីឲ្យយើងវិភាគទេ តែដើម្បីឲ្យយើងថ្វាយបង្គំវិញ។

ប៉ុន្តែ នៅពេលដែលយើងអានកណ្ឌគម្ពីរ កូឡូស ២:៩ «ដ្បិតមានគ្រប់ទាំងសេចក្តីពោរពេញរបស់ព្រះសណ្ឋិតនៅក្នុងទ្រង់ទាំងមានរូបអង្គផង» យើងនឹងកាន់តែពិបាកយល់អំពីការយាងមកយកកំណើតរបស់ទ្រង់។ ព្រះឱរសយេស៊ូវ ដែលគេបានរុំនឹងសំពត់ផ្តេកនៅក្នុងស្នូកសត្វ ក៏នៅតែជាព្រះដ៏គង់នៅគ្រប់ទីកន្លែងនៃចក្រវាឡទាំងមូលដដែល។ ការដែលព្រះអង្គគង់នៅគ្រប់ទីកន្លែង គឺជាលក្ខណៈសម្បត្តិមួយរបស់ទ្រង់ដែលយើងមិនអាចនិយាយរំលងបាន។ ព្រះអង្គមិនអាចមិនគង់គ្រប់ទីកន្លែងបានឡើយ។ ដូច្នេះ ចំពោះចំណុចដែលថា ព្រះយេស៊ូវគ្រីស្ទជាព្រះដែលបានយាងមកយកកំណើតជា

លោកគ្រូ លូវី ប៊័រខោថ៍ (Louis Berkhof) បានឯកភាពដោយលើកឡើងថា៖

"គោលជំនឿនៃការបង្កើត និងគោលជំនឿនៃការយាងមកយកកំណើតជាមនុស្ស តែងតែនាំមកនូវបញ្ហាមួយត្រង់កន្លែងដែលយើងព្យាយាមរកចំណុចភ្ជាប់ជាមួយនឹងការដែលថា ព្រះជាម្ចាស់មិនមានការបំផ្លាស់បំប្រែ... ប៉ុន្តែទោះជាយ៉ាងណា ក៏យើងនៅតែអាចដោះស្រាយបញ្ហានេះបានដែរ៖ យើងត្រូវតែទទួលស្គាល់ថា ភាពជាព្រះរបស់ព្រះជាម្ចាស់មិនបានទទួលការផ្លាស់ប្រែឡើយ នៅពេលដែលទ្រង់យាងមកយកកំណើតជាមនុស្ស"។[១]

លោកអ្នកប្រហែលជានិយាយថា "ថាម៉េច?"។ តើព្រះយេស៊ូវមិនបានឈប់រាប់សេចក្ដីដែលស្មើនឹងព្រះនោះ ទុកជាសេចក្ដីដែលគួរកាន់ខ្ជាប់ទេឬអី? មែន! ប៉ុន្តែ អ្វីដែលសាវ័ក ប៉ុល កំពុងនិយាយនៅក្នុងកណ្ឌគម្ពីរ ភីលីព ២:៥-៨ មិនមែនអំពីចំណុចដែលថា ព្រះយេស៊ូវលែង "រាប់" ឬក៏ "នៅរាប់" ភាពជាព្រះដ៏ពេញសិទ្ធិរបស់ទ្រង់ទេ ប៉ុន្តែអ្វីដែលសាវ័ក ប៉ុល កំពុងនិយាយនោះគឺអំពីចំណុចដែលថា ទ្រង់មិនបានយកផលប្រយោជន៍ ឬភាពស្មើនឹងព្រះមកទាស់នឹងបទពិសោធន៍នៃភាពជាមនុស្ស១០០%របស់ទ្រង់។ អាចនិយាយម្យ៉ាងទៀតបានថា ទ្រង់មិនបានទាញប្រឹងសង្គ្រោះបន្ទាន់ទេ។

ផ្ទុយទៅវិញ អ្វីដែលយើងមើលឃើញនៅក្នុងការអស្ចារ្យនៃការដែលព្រះយេស៊ូវជាព្រះផង និងជាមនុស្សផង គឺជាការពង្រីកដ៏អស្ចារ្យមួយ មិនមែនជាការបង្រួញនោះទេ។ ប្រាកដណាស់ ព្រះយេស៊ូវបាន "លះបង់ព្រះអង្គទ្រង់" (ភីលីព ២:៧) ប៉ុន្តែនេះមិនមែនមានន័យថា ទ្រង់បានបាត់បង់ភាពជាព្រះរបស់ទ្រង់ទេ តែផ្ទុយទៅវិញ វាជាការវាយតម្លៃទៅលើភាពសុញ្ញគំនិត

អំពីការយាងមកយកកំណើតជាមនុស្សប៉ុណ្ណោះ។ ការយាងមកយកកំណើតជាមនុស្ស គឺជាការដែលព្រះយេស៊ូវបានស្ម័គ្រព្រះទ័យក្នុងការដាក់ចុះនូវភាពជាព្រះរបស់ទ្រង់ ដោយបដិសេធមិនប្រើភាពជាព្រះនោះតាមដែលទ្រង់ចង់ប្រើ មិនមែនជាការដាក់ចុះបែបដកចេញនូវភាពជាព្រះរបស់ទ្រង់ចោលនោះទេ។ នេះមានន័យថា មិនមែនក្នុងពេលតែមួយ ទ្រង់បាត់បង់ភាពជាព្រះដោយព្រោះទ្រង់បានយាងមកយកកំណើតជាមនុស្ស ឬក៏ថាទ្រង់បានបាត់បង់ភាពជាមនុស្សដោយសារទ្រង់ជាព្រះនោះទេ។

លោកគ្រូ ចន ខាលវិន (John Calvin) បានលើកឡើងថា៖

«ដ្បិតសូម្បីតែព្រះបន្ទូលដែលមិនអាចវាស់ស្ទង់បាន នៅពេលដែលទ្រង់រួបរួមជាមួយមនុស្សក្លាយទៅជាបុគ្គលតែមួយ ក៏យើងមិនត្រូវគិតថា ទ្រង់បាត់បង់ភាពជាព្រះរបស់ទ្រង់ដែរ។ នេះជាចំណុចមួយដ៏អស្ចារ្យ៖ ព្រះរាជបុត្រានៃព្រះបានយាងចុះពីស្ថានសួគ៌មកផែនដីក្នុងលក្ខណៈដែលថា ទោះបីជាទ្រង់បានយាងមកយកកំណើតក្នុងផ្ទៃស្ត្រីក្រមុំព្រហ្មចារី ហើយរស់នៅលើផែនដីនេះ និងត្រូវបានគេឆ្កាងក៏ដោយ ក៏ទ្រង់មិនបានចេញពីស្ថានសួគ៌ដែរ ប៉ុន្តែទ្រង់បានបន្តគង់នៅលើពិភពលោកនេះ ដូចដែលទ្រង់បានគង់នៅតាំងពីដើមមកម្ល៉េះ»។[២]

តាមរយៈសម្ដីរបស់លោកគ្រូ ចន ខាលវិន (John Calvin) ការដែលព្រះបានយាងមកយកកំណើតជាមនុស្សតាមរយៈព្រះគ្រីស្ទ មិនមែនមានន័យថា ទ្រង់បានយាងចេញពីស្ថានសួគ៌នោះទេ តែគឺទ្រង់បានយាងចុះមកផែនដីនេះទេតើ ហើយវាលើសពីការដែលទ្រង់យាងចេញទៅទៀត។ នៅក្នុងសេចក្ដី

អត្ថាធិប្បាយរបស់គាត់អំពីកណ្ឌគម្ពីរ យ៉ូហាន គាត់បានសរសេរថា «ព្រះគ្រីស្ទដែល «គង់នៅស្ថានសួគ៌» បានបំពាក់សណ្ឋានជាមនុស្ស ដើម្បីឲ្យទ្រង់លូកព្រះហស្តរបស់ទ្រង់មកលើយើង ដើម្បីនឹងលើកយើងឡើងទៅស្ថានសួគ៌ជាមួយនឹងទ្រង់ផ្ទាល់»។[៣]

ចូរយើងទទួលយកចំណុចរបស់លោកគ្រូ ចន ខាលវិន (John Calvin)៖ នេះជាចំណុចមួយដ៏អស្ចារ្យ!

នៅថ្ងៃបុណ្យណូអែលនេះ ចូរយើងទទួលយកការអស្ចារ្យនៃការយាងមកយកកំណើតជាមនុស្សរបស់ព្រះគ្រីស្ទ ដែលការនោះបានសម្តែងឲ្យយើងឃើញអំពីភាពជាព្រះ១០០% និងជាមនុស្ស១០០%របស់ព្រះយេស៊ូវ ព្រោះការនោះបានប្រកាសដល់យើងអំពីដំណឹងល្អដ៏ធំបំផុតនៃភាពជាព្រះ១០០% សម្រាប់ភាពជាមនុស្ស១០០%។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ Jared Wilson
បកប្រែដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់ និងលោក អ៊ុន ជ័យរិទ្ធ
កែសម្រួលដោយ៖ លោក ជួប ប៊ុនហាក់, លោក អ៊ុន ជ័យរិទ្ធ, លោក ឈាង បូរ៉ា,លោក ទេព រ៉ូ, លោក ខែម បូឡុង,លោក ប៊ុន ធីម៉ូថេ,លោក ឯក សត្យានិង លោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.desiringgod.org/articlesthe-christmas-miracle-of-the-incarnation-of-the-omnipresent-word ដោយមានការអនុញ្ញាត។

# ១០ វេលាកំណត់បានមកដល់

“តែលុះវេលាកំណត់បានមកដល់ នោះព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រិត្យវិន័យ” (កាឡាទី ៤:៤)។

ខគម្ពីរមួយនេះប្រកាសអំពីការដែលព្រះជាម្ចាស់ចាត់ព្រះរាជបុត្រារបស់ទ្រង់ក្នុង “វេលាកំណត់បានមកដល់”។ មានព្រឹត្តិការណ៍ជាច្រើនបានកើតឡើងក្នុងអំឡុងពេលនៃសតវត្សទី១ យ៉ាងហោកណាស់តាមរយៈការគិតគូររបស់យើង ពេលនោះគឺជាពេលដ៏ល្អក្នុងការឲ្យព្រះយេស៊ូវយាងមក។

តើមានមូលហេតុអ្វីបានជាព្រះជាម្ចាស់ចាត់ព្រះយេស៊ូវក្នុងវេលាដែលទ្រង់បានកំណត់ឲ្យទៅ? ហេតុអ្វីបានជាមិនចាត់មកមុនហ្នឹង? ហេតុអ្វីបានជាមិនចាត់ក្រោយហ្នឹង?

១. នៅគ្រានោះក្នុងចំណោមសាសន៍យូដាមានការទន្ទឹងរងចាំយ៉ាងខ្លាំងថា ព្រះមេស្ស៊ីនឹងយាងមក។ ការដែលពួករ៉ូមត្រួតត្រាលើសាសន៍អ៊ីស្រាអែលធ្វើឲ្យសាសន៍យូដាមានការស្រេកឃ្លានយ៉ាងខ្លាំងក្នុងការឲ្យព្រះមេស្ស៊ីយាងមក។

២. ក្រោមការត្រួតត្រារបស់ពួករ៉ូម ពួកគេបាននាំឲ្យពិភពលោកមានការរួបរួមគ្នា ដែលការនោះផងដែរបានផ្ដល់ឲ្យផ្នែកនានានៃទឹកដីមួយចំនួនមានការរួបរួមគ្នា។ ហើយដោយសារចក្រភពមានសន្តិភាព នោះការធ្វើដំណើរក៏អាចទៅរួចបាន ដែលការនោះបានអនុញ្ញាតឲ្យគ្រីស្ទបរិស័ទគ្រាដំបូងអាចផ្សព្វផ្សាយដំណឹងល្អបាន។ បើនៅគ្រាយុគសម័យក្រៅពីនេះ នោះសេរីភាពនៃការធ្វើដំណើរមិនអាចទៅរួចបានឡើយ។

៣. ក្នុងខណៈពេលដែលពួករ៉ូមបានយកឈ្នះខាងកងទ័ព ពួកក្រិកបានយកឈ្នះខាងប្រពៃណី។ សណ្ឋាននៃភាសា “សាមញ្ញ” របស់ពួកក្រិក (ខុសគ្នាពីអក្សរសិល្ប៍ក្រិក) គឺជាភាសាពាណិជ្ជកម្ម ហើយក៏ជាភាសាដែលគេប្រើប្រាស់ក្នុងចក្រវាលទាំងមូល ដែលការនោះហើយធ្វើឲ្យការផ្សព្វផ្សាយដំណឹងល្អទៅរួចបាន ទៅកាន់ពួកក្រុមមនុស្សជាច្រើនទៀតតាមរយៈភាសាដ៏សាមញ្ញតែមួយ។

៤. ធាតុពិតត្រង់ថា ការថ្វាយបង្គំព្រះក្លែងក្លាយជាច្រើនបាននាំឲ្យពួកគាត់បរាជ័យក្នុងការយកឈ្នះលើពួករ៉ូម ដែលបានយកឈ្នះលើពួកគាត់ ដែលការនោះបានបណ្ដាលឲ្យអ្នកថ្វាយបង្គំបោះបង់រូប

ព្រះក្លែងក្លាយទាំងអស់នោះចោល។ ស្របគ្នានោះដែរ ក្នុងទីក្រុងដែលមានបែបបទប្រពៃណីល្អជាងទីក្រុងមួយចំនួន ទស្សនវិជ្ជា និងវិទ្យាសាស្ត្ររបស់ពួកក្រិកនៅគ្រានោះបាននាំឲ្យមនុស្សមួយចំនួនមានភាពទទេស្អាតខាងឯព្រលឹងវិញ្ញាណ ដូចគ្នាផងដែរ ក្នុងរបៀបដែលពួកគ្មានសាសនានៃពួកកុម្មុយនីស្តនាំឲ្យមានភាពទទេស្អាតខាងឯព្រលឹងវិញ្ញាណសព្វថ្ងៃនេះដែរ។

៥. សាសនាបែបអាថ៌កំបាំងមួយចំនួននៅគ្រានោះផ្តោតលើព្រះ—សង្គ្រោះ ហើយទាមទារអ្នកថ្វាយបង្គំឲ្យបូជាឈាម ដែលការនោះធ្វើឲ្យដំណឹងល្អរបស់ព្រះគ្រីស្ទដែលមានរួមបញ្ចូលទាំងការធ្វើយញ្ញបូជាចុងក្រោយអាចជាការជឿជាក់បានចំពោះពួកគេ។ ពួកសាសន៍ក្រិកក៏ជឿលើភាពអមតៈនៃព្រលឹងវិញ្ញាណដែរ (ប៉ុន្តែមិនជឿទៅលើរូបកាយឡើយ)។

៦. ពួកកងទ័ពរ៉ូមក៏បានជ្រើសរើសពួកទាហានចេញពីតាមតំបន់ខេត្តនានា ហើយណែនាំទាហានទាំងនោះឲ្យស្គាល់ប្រពៃណីពួករ៉ូម និងគំនិតគិតគូរ (ដែលមានដូចជាដំណឹងល្អជាដើម) ដែលមិនទាន់បានឈានទៅដល់ជាយខេត្តមួយចំនួននោះនៅឡើយទេ។ ការណែនាំដំណឹងល្អដំបូងបង្អស់ទៅកាន់ពួកប្រទេសអង់គ្លេសគឺជាលទ្ធផលនៃការដែលពួកទាហានគ្រីស្ទបរិស័ទទៅបោះទីតាំងនៅទីនោះ។

ចំណុចទាំងប៉ុន្មាននៅខាងលើនេះគឺគ្រាន់តែជាការដែលមនុស្សយើងសង្កេតមើលលើពេលវេលា ហើយគ្រាន់តែសន្មតអំពីមូលហេតុដែលនៅចំណុចពេល

វេលានោះក្នុងប្រវត្តិសាស្ត្រ គឺជាពេលវេលាដ៏ល្អក្នុងការដែលព្រះគ្រីស្ទយាងមក តែប៉ុណ្ណោះ។ ប៉ុន្តែ យើងយល់ឃើញថា របៀបរបស់ព្រះជាម្ចាស់គឺមិនមែនជារបៀបរបស់យើងឡើយ (អេសាយ ៥៥:៨) ហើយចំណុចទាំងប៉ុន្មានទំនង ឬក៏មិនទំនងជាមូលហេតុដែលព្រះអង្គជ្រើសរើសចាត់ព្រះរាជបុត្រារបស់ទ្រង់ក្នុងពេលវេលានោះផងដែរក៏មិនដឹង។ យោងតាមកណ្ឌគម្ពីរកាឡាទីជំពូក៣ និង៤ យើងឃើញយ៉ាងច្បាស់ថា ព្រះជាម្ចាស់ព្យាយាមចាក់គ្រឹះតាមរយៈក្រឹត្យវិន័យរបស់សាសន៍យូដា ដែលនឹងរៀបចំសម្រាប់ការដែលព្រះមេស្ស៊ីយាងមក។ គោលបំណងនៃក្រឹត្យវិន័យគឺ ដើម្បីជួយឲ្យមនុស្សយល់អំពីជម្រៅនៃភាពអាក្រក់នៃអំពើបាបរបស់ខ្លួន (ត្រង់ថាពួកគេមិនមានលទ្ធភាពក្នុងការត្រាប់តាមក្រឹត្យវិន័យនោះឡើយ) ដើម្បីឲ្យពួកគេទំនងជាអាចត្រៀមខ្លួនក្នុងការទទួលការព្យាបាលអំពើបាបរបស់ពួកតាមរយៈព្រះយេស៊ូវដែលជាព្រះមេស្ស៊ី (កាឡាទី ៣:២២-២៣; រ៉ូម ៣:១៩-២០)។ ក្រឹត្យវិន័យក៏ «ធ្វើជាអ្នកដឹកនាំ» មនុស្សទៅកាន់ព្រះយេស៊ូវជាព្រះមេស្ស៊ីដែរ (កាឡាទី ៣:២៤)។ វាបានធ្វើបែបនោះតាមរយៈការលើកឡើងជាទំនាយទាក់ទងទៅនឹងព្រះមេស្ស៊ីដែលព្រះយេស៊ូវបានបំពេញ។ លើសពីនោះទៅទៀតគឺការធ្វើយញ្ញបូជាដែលចង្អុលបង្ហាញទៅលើតម្រូវការទាក់ទងនឹងយញ្ញបូជាចំពោះអំពើបាប ក៏ដូចជាការដែលវាមិនអាចបំពេញបានដោយខ្លួនឯង (ដោយថាយញ្ញបូជានីមួយៗតែងតែតម្រូវឲ្យមានយញ្ញបូជាមួយទៀតថែមពីលើ)។ ប្រវត្តិសាស្ត្រនៃព្រះគម្ពីរសញ្ញាចាស់ក៏បានផាត់ជាពណ៌អំពីបុគ្គល និងព័ន្ធកិច្ចរបស់ព្រះគ្រីស្ទតាមរយៈព្រឹត្តិការណ៍មួយចំនួន និងការជប់លៀងខាងឯ

សាសនា (ឧទាហរណ៍៖ ការដែលលោក អ័ប្រាហាំ ស្ម័គ្រចិត្តក្នុងការថ្វាយលោក អ៊ីសាក ឬក៏ការពណ៌នាយ៉ាងលម្អិតអំពីថ្ងៃបុណ្យរំលងនៅពេលដែលសាសន៍អ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទ។ល។)។

ជាចុងក្រោយ ព្រះគ្រីស្ទបានយាងមកនៅពេលដែលព្រះអង្គបានយាងមកក្នុងការបំពេញទំនាយដ៏ជាក់លាក់។ កណ្ឌគម្ពីរ ដានីយ៉ែល ៩:២៤-២៧ បាននិយាយរៀបរាប់អំពី «៧០អាទិត្យ» ឬក៏ ៧០ «ប្រាំពីរ»។ ដោយយោងទៅតាមបរិបទ «អាទិត្យ» ទាំងនេះ ឬក៏ «ប្រាំពីរ» និយាយសំដៅទៅលើក្រុមនៃប្រាំពីរឆ្នាំ មិនមែនប្រាំពីរថ្ងៃទេ។ បើយើងអាចពិនិត្យមើលប្រវត្តិសាស្ត្រ ហើយរៀបរាប់ពីចំណុចលម្អិតនៃ ហុកសិបប្រាំបួនអាទិត្យដំបូង (អាទិត្យទីចិតសិបនឹងកើតឡើងនៅឯអនាគត)។ ការរាប់ចុះនៃ «៧០អាទិត្យ» ចាប់ផ្តើមជាមួយនឹងការ «បង្គាប់ឲ្យតាំងក្រុងយេរូសាឡឹម ហើយសង់ឡើងវិញ» (ខ២៥)។ ស្តេចអើថាសើកសេស ឡុងហ្គីម៉ានូស៍ (Artaxerxes Longimanus) បានចេញរាជសារនៅឆ្នាំ ៤៤៥ មុនគ.ស. (នេហេមា ២:៥)។ បន្ទាប់ពីប្រាំពីរ «ប្រាំពីរ» បូកជាមួយនឹង ៦២ «ប្រាំពីរ» ឬក៏ ៦៩ គុណនឹង ៧ ឆ្នាំ ទំនាយក៏បានលើកឡើងដូចតទៅ «នោះអ្នកដែលបានចាក់ប្រេងតាំងឡើង នឹងត្រូវផ្តាច់ចេញវិញ ឥតមានទាក់ទងនឹងអ្វីឡើយ រួចបណ្តាទ័ពរបស់ចៅហ្វាយ១ដែលនឹងមក គេនឹងបំផ្លាញទីក្រុង នឹងទីបរិសុទ្ធ» (ខ២៦)។ នៅត្រង់នេះ យើងមានខគម្ពីរយោងដែលមិនអាចភ័ន្តច្រឡំបានទាក់ទងទៅនឹងការសុគតរបស់ព្រះសង្គ្រោះនៅលើឈើឆ្កាង។ មួយសតវត្សមុននេះ ក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងជាភាសាអង់គ្លេសថា The Coming Prince លោកគ្រូ

ស័រ រ៉ូបើត អនឌឺសិន (Sir Robert Anderson) បានផ្តល់ជូនការទូទាត់យ៉ាងលម្អិតអំពីហុកសិបប្រាំបួនអាទិត្យ ដោយប្រើប្រាស់ "ឆ្នាំនៃទំនាយ" ដោយអនុញ្ញាតឲ្យមានឆ្នាំរំលង កំហុសឆ្គងក្នុងប្រតិទិន ការប្តូរចេញពី មុនគ.ស. ទៅ គ.ស. ហើយបានរកឃើញថា ហុកសិបប្រាំបួនអាទិត្យបានចប់នៅថ្ងៃដែលព្រះយេស៊ូវបានយាងចូលមកក្នុងទីក្រុងយេរូសាឡឹម ប្រាំថ្ងៃមុនទ្រង់សុគត។ មិនថាបុគ្គលណាម្នាក់ប្រើប្រាស់ ឬក៏មិនប្រើប្រាស់ការវិភាគមួយនេះក៏ដោយ ក៏ត្រង់ចំណុចនេះគឺថា ពេលវេលានៃការដែលព្រះគ្រីស្ទយាងមកយកកំណើត ក៏មានភាពស៊ីគ្នាក្នុងទំនាយយ៉ាងលម្អិតដែលហោរា ដានីយ៉ែល បានកត់ទុកប្រមាណជាង ៥00 ឆ្នាំមុនដែរ។

ពេលវេលានៃការដែលព្រះគ្រីស្ទបានយាងមកយកកំណើត គឺបានកើតឡើងក្នុងលក្ខណៈដែលថា មនុស្សម្នានៅគ្រានោះបានត្រៀមខ្លួនរួចជាស្រេចក្នុងការយាងមករបស់ព្រះអង្គ។ ចាប់តាំងពីពេលនោះមក មនុស្សគ្រប់សតវត្សមានភស្តុតាងយ៉ាងគ្រប់គ្រាន់អំពីព្រះយេស៊ូវដែលថា ទ្រង់ពិតជាព្រះមេស្ស៊ីដែលត្រូវបានសន្យាឡើងមែន តាមរយៈការដែលព្រះអង្គបានបំពេញព្រះបន្ទូលដែលមានបង្ហាញជារូបភាព និងទំនាយអំពីការយាងមករបស់ទ្រង់យ៉ាងលម្អិតផងដែរ។

ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ
និពន្ធដោយ៖ ក្រុម Got Questions
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ,លោក ឈាង បូរ៉ា, លោក ខែម បូឡុង,លោកស្រី ឡូញ ស្រីរដ្ឋ, លោក ធីម៉ូថេ ប៊ុន, លោក ឯក សត្យា និងលោក ឯក ធីម៉ូថេ
ដកស្រង់ខ្លះៗចេញពី https://www.gotquestions.org/fullness-of-time.html ដោយមានការអនុញ្ញាត។

# កំណត់យោង

**ជំពូកទី៩**

១. លោក Louis Berkhof, “Systematic Theology” (Grand Rapids, Michigan: Eerdmans, ឆ្នាំ១៩៩៦), ទំព័រ៣២៣-៣២៤។

២. លោក John Calvin, “Institutes of the Christian Religion”, កែសម្រួលដោយ៖ លោក John T. McNeill, Vol. 1, 2.XIII.iv (Philadelphia: Westminster, ឆ្នាំ១៩៦០), ទំព័រ៤៨១។

៣. លោក John Calvin, Crossway Classic Commentaries, Packer (Wheaton: Crossway, ឆ្នាំ១៩៩៤) ទំព័រ៧៤-៧៥។ យ៉ូហាន ១៧:២១។

# អានបន្ថែមនៅ៖

ផ្លូវពិត
plovpit.com

**For ordering information please visit:**

ប្រសិនបើលោកអ្នកចង់បានសៀវភៅនេះ

សូមចូលទៅកាន់គេហទំព័រ៖

http://www.themeaningofchristmaskhmer.com

# ហើយទាញយកសៀវភៅជា ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com